# ប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា

១- កម្ពុជា នៅសម័យដើម ៖ ឥទ្ធិពល ឥណ្ឌា និង កម្ពុជា ◆ នគរភ្នំ មន ◆ សៀម ◆ ចាម្ប៉ា ◆ សូរិយាវរ្ម័នទី២ ◆ ជ័យវរ្ម័នទី៧

២- សៀម និង ការបាត់បង់ អាណាខេត្រខ្មែរ ខាងលិច ◆ កុម្មុយនិស្តឥណ្ឌូចិន កុម្មុយនិស្ត និង កម្ពុជា ◆ ការបាត់បង់ ទឹកដីកម្ពុជាក្រោម

៣- ដំណុះ រាស្ត្រខ្មែរ ◆ ការគ្រប់គ្រង រដ្ឋបាល ◆ ជំរឿនប្រជាជន លទ្ធផល នៃ ការបោះឆ្នោតជាតិ ◆ កាលប្រវត្តិវិជ្ជា ឆ្នាំ ១៨៣៥-២០១២

# ប្រវត្តិរូប ឥស្សរជន ខ្មែរ (១០៧ នាក់)

អង្គឌួង - ប៊ីវ ឆាយលាង - ប៊ុន ចន្ទម៉ុល - ចន្ទរាជា - ចាន់ ណាក - ចាន់យូរ៉ាន់ - ចៅ សែនកុសល - ចៅ សេង - ចៅ សេងអួរ - ជា ស៊ីម - ឈាន វ៉ម - ចេង ហេង - ឆេង ផុន - ជួន ណាត - ខិត ខៀវ - ឈូក ម៉េងម៉ៅ - ជាប ឈួន - ឌុក រ៉ាស៊ី - ឌីផុន ប៉ូលីន - ហ៊ែល ស៊ុមផា - ហែម ចៀវ - ហេង សំរិន - ហ៊ូ យន់ - ហ៊ុយ នឹម - ហង្ស ធុនហាក់ - ហ៊ុន សែន - ហូ តុងលិប - ហ៊ុយ កន្ធុល - អ៊ិន តាំ - អៀង សារី - អៀង ភើស - ស្តេចកន - កាំង ហ្កេកអ៊ាវ ហៅ ឌុច - កឹក ប៊ុនប៉ុង - កឹម សុខា - កេង វ៉ាន់សាក់ - ខៀវ សំផន - ខៀវ ធីបូទ្ធិ - ឃឹង ហុកឌី - ឃឹម ទិត - ឃិន សុខ - គិរម្យ ទ៉ុយ - ឡេងងែត - ឡុង សៀម - លន់ នល់ - លន់ ណុន - ឡុង បូរេត - ឡុង ប៊ុនរួត ហៅ នួន ជា - ញ៉ុក ថែម - នរោត្តម - នរោត្តម យុគន្ធរ - នរោត្តម សុរាម្រិត - នរោត្តម សីហនុ - នរោត្តម សីហមុនី - នរោត្តម ចន្ទរង្សី - នរោត្តម រណឫទ្ធិ - នរោត្តម កន្តុល - ញឹក ជូឡុង - ញឹក ប៊ុនឆៃ - នូ ហាច - នូ កន - នួន ឃឿន - សុតន្តប្រីជា ឥន្ទ - អ៊ុម ឈាងស៊ុន - ប៉ាង ខាត់ - ប៉ែន សុវណ្ណ - ប៉ែន នុត - ផូ ព្រឿង - ត្អូង តុន - ប៉ុល ពត (សាឡុតស) - ពៅ សាវរស - រស់ ចន្ទ្រាបុត្រ - រឹម គីន - សារិន ឆាក - សាន យុន - សាគូ សាម៉ុត - សម សារី - សម រង្ស៊ី - ស៊ីសុវត្ថិ - ស៊ីសុវត្ថិ មុនីវង្ស - ស៊ីសុវត្ថិ មុនីពង្ស - ស៊ីសុវត្ថិ យុត្តិវង្ស - ស៊ីសុវត្ថិ សិរិមតៈ - ស៊ីសុវត្ថិ មុនីរ៉េត - ស៊ីសុវត្ថិ វត្តឆាយាវង្ស - ស៊ីសុវត្ថិ ឥស្សរា - ស៊ិន ស៊ីសាមុត - ស៊ាន ប៉េងសែ - ស៊ុម វ៉ា - ស៊ឹន សាន - ស៊ឺង ង៉ុកថាញ់ - ស៊ឺង ង៉ុកមិញ - សុន សេន - សុទ្ធ ប៉ូលិន - ស៊ឹន ដៀប - វ៉ាំង ជួន - តាន់ គឹមហួន - ទេព ផន - ទ្រិញ វ៉ាញ - ទ្រៀង កាង - ត្រឹង ងា - ត្រឹង ងា (អ្នកស្រី) - តាម៉ុក - ទីវ អុល - អ៊ុង ក្រពុំផ្កា - វ៉ាន់ឌី កាអុន - យ៉ែម សំបូរ

*Editions* ANGKOR
#143Eo Khémarak Phoumin (St.130) Phnom Penh, Cambodge
Dépôt légal : Bibliothèque nationale de France - Janvier 2013
ISBN : 2-9524557-3-2 ISSN : 1162-1680

សាគូ សាម៉ុត

ប្រវត្តិសាស្ត្រកម្ពុជា និង ឥស្សរជន ខ្មែរ

បណ្ណាគារ អង្គរ

## សាគូ សាម៉ុត

# ប្រវត្តិសាស្ត្រកម្ពុជា និង ឥស្សរជន ខ្មែរ







# HISTOIRE DU CAMBODGE ET ÉLITES KHMÈRES

គ្រឹះស្ថានបោះពុម្ព អង្គរ • ភ្នំពេញ ២០១៣ • រក្សាសិទ្ធិ អ្នកនិពន្ធ

# ជំពូក ២
# សៀម និង ការបាត់បង់ អាណាខេត្តខ្មែរ ខាងលិច

ព្រះរាជាណាចក្រអង្គរ លាតសន្ធឹងនៅលើផ្ទៃដីមួយភាគធំ នៃ ជ្រោយឥណ្ឌូចិន និង មានប្រជាជនប្រមាណ ១៥ លាន នាក់ ។ នៅឆ្នាំ ១៩៤៥ ព្រះរាជាណាចក្រនេះ មានផ្ទៃដី ប្រហែល ២/៣ នៃ ប្រទេសកម្ពុជា សព្វថ្ងៃ (១២០.៧០០ គម$^{២}$) និង មានប្រជាជន ប្រមាណ ៨ សែន នាក់ ។

បុព្វហេតុ បី យ៉ាង ដែលធ្វើឲ្យ កម្ពុជា បាត់បង់ទឹកដី ៖

១.- រចនាសម្ព័ន្ធសង្គមខ្មែរមិនរឹងមាំ មានអំពើអយុត្តិធម៌ក្នុងសង្គម ។

២.- វិបត្តិក្នុងរាជវង្សខ្មែរ បណ្ដាលឲ្យមានចម្បាំងក្នុងស្រុក ។

៣.- ការឈ្លានពានទន្ទ្រានយកទឹកដីពី សៀម និង យួន ។

## សៀមឈ្លានពាន និង ការធ្លាក់បន្ទាយលង្វែក

សៀម មានកំណើតពី កុលសម្ព័ន្ធ “ថៃ” មានកំណើតនៅ ណានចៅ នៅខាងត្បូង ស្រុកចិន ម្ដុំខេត្តយន់ណាន ។ នៅសតវត្សទី ៨ ណានចៅ ជាសាមន្តរដ្ឋមួយរបស់អធិរាជ ចិន នៃ **សន្តតិវង្សតង់** ។ នៅសតវត្សទី ១៣ ប្រទេសចិន ប៉ែកខាងត្បូង ត្រូវទ័ពម៉ុងហ្គោល កាន់កាប់ និង បានរុញ កុលសម្ព័ន្ធជាច្រើន ឲ្យចុះមកក្រោម មកជ្រោយឥណ្ឌូចិន ។ ដើម្បី ងាយស្រួលក្នុងជីវភាពរស់នៅ អ្នកទាំងនោះ ច្រើនមកផ្ដុំរស់តាមដីសណ្ដរទន្លេ ៖ ទន្លេខ្មៅ ទន្លេក្រហម ទន្លេមេគង្គ ទន្លេមេណាម ទន្លេសាល់វីន ទន្លេអ៊ីរ៉ាវ៉ាឌី និង ទីកន្លែងមានបឹងបួ ។

- នៅប៉ែកខាងកើត **ទន្លេខ្មៅ ទន្លេក្រហម** នៃ រាជាណាចក្រ ដៃវៀត ពួកថៃ ត្រូវ

បានពួកវៀត (យួន) ខ្ទប់ មិនឲ្យចុះមកក្រោម ។

• នៅប៉ែកខាងលិច តាមទន្លេ**សាលីវីន** និង **អ៊ីរ៉ាវ៉ាឌី** ពួកថៃ ក៏ពុំបានរីកទេ ព្រោះពួកភូមា ដែលមានរួមប្រជុំកុលសម្ព័ន្ធជាច្រើន បានមកខ្ទប់ មិនឲ្យ ថៃ រីករាលដាលបានឡើយ ។

• មានតែប៉ែកខាងត្បូង តាម**ទន្លេមេគង្គ** ជាពិសេស **ទន្លេមេណាម** ដែល ពួកថៃបានរីកដាលយ៉ាងសម្បើម ។ ម្យ៉ាង ទឹកដីទាំងនោះជា រាជាណាចក្រខ្មែរ តែ ខ្មែររស់នៅរាជាណាចក្រប៉ែកខាងជើង មានចំនួនតិចជាង ខ្មែររស់នៅក្នុងរាជាណាចក្រប៉ែកខាងត្បូង ។ កំណកំណើតរាជាណាចក្រខ្មែរ មាន ពីក្រោមទៅលើ ឬ ពីត្បូងទៅជើង ៖ នគរភ្នំ ចេនឡា ចក្រភពអង្គរ ។ នៅប៉ែកខាងជើង ដោយមានការ យោគយល់ និង អាណិតអាសូរ ពីព្រះមហាក្សត្រខ្មែរផង មាន សៀម (ថៃ) ខ្លះ ត្រូវបានលើកតំកើងរហូតជាមន្ត្រីដឹកនាំទៀតផង ។ នៅចន្លោះឆ្នាំ ១២២០-១២៣៨ បងប្អូនសៀមពីរនាក់ បានបះបោរ ហើយបានដេញកំចាត់ចៅហ្វាយខេត្តខ្មែរ ចេញពីក្រុង "សុខោទ័យ" ទីក្រុង ដែលពេលក្រោយមកក្លាយជា "សុខោថៃ" ។ នៅឆ្នាំ ១៩៣៩ ក្នុងបំណងរួមផ្តុំកុលសម្ព័ន្ធនានា ដែលនិយាយភាសា "ថៃ" រដ្ឋាភិបាលសៀម បានបង្កើតពាក្យនេះឡើង ។ កុលសម្ព័ន្ធថៃ នៅប្រទេសសៀម មាន ៨០% គឺសំដៅកុលសម្ព័ន្ធទាំងឡាយណា ដែលនិយាយថៃ ។ ចំពោះ ខ្មែរយើង យើងហៅតែ "សៀម" ដដែល ដូចជាមានរូបចម្លាក់នៅប្រាសាទអង្គរវត្ត ជាតឹកតាង ដែលមានទាហានស៊ីឈ្នួលសៀម ដែលខ្មែរបានជួលមកធ្វើសង្គ្រាម ដើម្បីទៅវាយពួកវៀត "យួន" ។

## ព្រះបាទ ស្រីសុគន្ធបទ (១៥០៨-១៥១២)

នៅពេល ព្រះបាទ ធម្មរាជា ចូលទីវង្គត នៅឆ្នាំ ១៥០៤ បុត្រច្បងគឺ ចៅ **ពញាដាំ-ខាត់រាជា** បានឡើងគ្រងស្នងព្រះអង្គ ដោយមាននាមសំរាប់រាជ្យថា **ព្រះស្រីសុគន្ធបទ** គង់នៅរាជធានី ចតុមុខ ។ បន្ទាប់មក ព្រះស្រីសុគន្ធបទ បានលើករាជធានីមកតាំងនៅ **ទួលបាសាន** ។ ព្រះអនុជ នាម **ពញាចន្ទរាជា** បានតែងតាំងជាមហាឧបរាជ នៅឆ្នាំ ១៥០៨ ដើម្បី ការពារក្រុងចតុមុខ និង មើលអាណាខេត្តត្រើយខាងលិច ។ ព្រះស្រីសុគន្ធបទ បានធ្វើសង្គ្រាមជាមួយស្តេចពានរាជ្យ គឺ **ស្តេចកន** ដែលទីបំផុត ព្រះស្រីសុគន្ធបទ ត្រូវក្រុមស្តេចកន ធ្វើគតនៅបន្ទាយស្ទឹងសែន នៅឆ្នាំ ១៥១២ ។ (សូមអាន ស្តេចកន)

ស្តេចកន មានអាយុ ២៩ ឆ្នាំ បានឡើងគ្រងរាជ្យមាននាម **ព្រះស្រីជេដ្ឋាធិរាជ-រាមាធិបតី** ។ ទ្រង់បានលើករាជធានីមកតាំងនៅ **ចន្លក់ដូនតី** (បាន ៥ ខែ) រួចលើកមកតាំងនៅ ភូមិស្រឡប់ ជាទល់ដែន ខេត្តត្បូងភ្នំ និង ខេត្តបាភ្នំ រាជធានីថ្មីនេះ មានឈ្មោះ



ថា ***ក្រុងស្រឡប់ពិជ័យព្រៃនគរ*** ។

## ចម្បាំងរវាង ព្រះបាទ ស្រីជេដ្ឋា និង ព្រះចន្ទរាជា (១៥១៦-១៥២៥)

ព្រះចន្ទរាជា ជាព្រះអនុជ ព្រះស្រីសុគន្ធបទ ជាមួយព្រះរាជវង្សានុវង្ស បានភៀសខ្លួនទៅសុំជ្រកកោននឹងស្តេចស្រុកសៀម នៅពេលដឹងថា ស្តេចកន ក្បត់ ។ នៅស្រុកសៀម ព្រះចន្ទរាជា តែងតែទៅទាក់ដំរី យកដំរីថ្វាយស្តេចស្រុកសៀម ។ ពេលដែលដឹងថា ព្រះរៀម បានត្រូវបក្សពួក ស្តេចកន ធ្វើគតហើយ ទ្រង់ក៏រកមធ្យោបាយវិលត្រឡប់មកស្រុកខ្មែរវិញ ។ ទ្រង់បានប្រឌិតថា ទៅទាក់ដំរីស នៅប៉ែកខាងកើតស្រុកសៀម ។ ដំរីសនោះមានកំពស់ ១០ ហត្ថ (៥ ម៉ែត្រ) ។ ព្រះចៅសៀម បានព្រមឲ្យពលចំនួន ៥០០ នាក់ ដំរីធ្នាក់ ៥០ គ្រឿងសាស្ត្រាវុធ ស្បៀងអាហារ និង ដាវអាជ្ញាសឹក ។ ព្រះចន្ទរាជា មិនបានទាក់ដំរីសទេ តែបាននាំទ័ពចូលស្រុកខ្មែរ ទៅដល់ បាត់ដំបង បានកែនពល ១០០០០ នាក់ ហើយលើកទ័ពឆ្ពោះទៅ ពោធិ៍សាត់ ។ តាពេជ ជាមេទ័ពជំនិត ព្រះចន្ទរាជា បានវាយយក ខេត្តក្រគរខ្លុងក្រង ។ នៅឆ្នាំ ១៥២៥ ព្រះចន្ទរាជា បានចាត់ឲ្យទៅទិញកាំភ្លើង ធំតូច ពីប្រទេសម៉ាឡាយូ ដើម្បីវាយផ្តាច់ព្រាត់ទៅទ័ព ព្រះស្រីជេដ្ឋា ។ ទ័ព ព្រះចន្ទរាជា ចែកជា បី ផ្លូវ ។ ព្រះអង្គ ទ្រង់នាំទ័ពទៅវាយ**បន្ទាយស្រីសឈរ** (ស្រីសន្ធរ) ដោយផ្ទាល់ព្រះអង្គ ។ ព្រះស្រីជេដ្ឋា និង ចៅហ្វាកៅ (មន្ត្រីក្បត់) ខំវាយទម្លុះរត់ចូលទៅក្នុង **បន្ទាយស្រឡប់ពិជ័យ** ដែលទីបំផុត បន្ទាប់ពីបានតស៊ូ បីខែ មក ទ័ពព្រះស្រីជេដ្ឋា បានទទួលបរាជ័យ ។ ព្រះស្រីជេដ្ឋា ត្រូវគេកាត់ព្រះសិរ យកមកដោតនៅមុខបន្ទាយ ក្រុងស្រឡប់-ពិជ័យ ឯចំណែក ចៅហ្វាកៅ ក៏ត្រូវគេសម្លាប់បានក្នុងបន្ទាយនោះដែរ ។ សង្គ្រាមក្នុងស្រុកមានរយៈពេល ៩ ឆ្នាំ (១៥១៦-១៥២៥) បានបញ្ចប់នៅពេលនោះ ។

ព្រះចន្ទរាជា បានឡើងគ្រងរាជ្យនៅឆ្នាំ ១៥១៦ មាននាម **ព្រះចន្ទរាជា** ក្រោយពេលរកឃើញ ព្រះខ័ណរាជ្យ លំពែងជ័យ និង គ្រឿងបច្ចក្សេត្រ ។ ព្រះអង្គ មានរាជធានីតាំងជាបណ្តោះអាសន្ននៅក្នុង ខេត្តពោធិ៍សាត់ ។ បន្ទាប់មក ព្រះអង្គក៏លើករាជធានីមកគង់នៅ **ក្រុងលង្វែក** ។ រាជធានីថ្មីនេះ ត្រូវបានកសាងប្រហែល ៣ ឆ្នាំ (១៥២៧-១៥២៩) ។

ពេលដែលដឹងថា ព្រះចន្ទរាជា កាន់អំណាចស៊ប់នៅ ប្រទេសខ្មែរ ហើយ ព្រះចៅសៀម ក៏បានទាមទារយកស្នួយសារអាករពីស្តេចប្រទេសខ្មែរ ដែលប្រទេសនេះ ធ្លាប់បានផ្តល់ឲ្យតាំងពីរាជ្យ ព្រះបាទ ស្រីធម្មរាជាទី ១ (១៤៨៦-១៥០៤) ។ ព្រះចន្ទរាជា ពុំព្រម ។ សៀម បានលើកទ័ពមកលុកលុយ ខេត្តអង្គរ ។ ព្រះអង្គ បានលើកទ័ពខ្មែរទៅតទល់នៅត្រង់ **ស្ទឹងអង្គរ** ត្រង់ភូមិមួយឈ្មោះថា **សៀមរាប** គឺជាអនុស្សាវរីយ៍ដែលទ័ពខ្មែរបាន

ទទួលជោគជ័យលើ ទ័ពសៀម ឈ្លានពាន ។ ដើម្បីជាការសងសឹក នៅឆ្នាំ ១៥៣០ ព្រះចៅសៀម បានបញ្ជា **ពញាអុង** “បុត្រ ព្រះស្រីរាជា (១៤៦៩-១៤៨៥) ក្លាយជាបុត្រធម៌ព្រះចៅសៀម និង បានកាន់តំណែងជា ចៅហ្វាយខេត្ត**សុវណ្ណខាត់លោក**” លើកទ័ព ៩ ម៉ឺននាក់ មកវាយខ្មែរម្តងទៀត ។ ព្រះចន្ទរាជា បានលើកទ័ពទៅតទល់គ្នានៅ ពោធិ៍សាត់ ។ ទ័ពសៀមជើងទឹក ក៏បានឡើងគោកនៅឈូងសមុទ្រសៀមដែរ តែត្រូវទ័ពខ្មែរវាយបាក់វត់ខ្ចាត់ខ្ចាយទៅ ។ នៅសមរភូមិពោធិ៍សាត់ មេទ័ពសៀមបានស្លាប់អស់ជាច្រើន ក្នុងនោះមាន ពញាអុង ផងដែរ ដោយបានត្រូវព្រួញស្លាប់លើខ្នងដំរី ។ ឯពលទាហានសៀម ស្លាប់អស់ពាក់កណ្តាល ដំរីងាប់អស់ជាច្រើន អាវុធយុទ្ធភ័ណ្ឌ ត្រូវបានរឹបអូសយកយ៉ាងសន្ធឹក-សន្ធាប់ ។ ព្រះចន្ទរាជា បានបញ្ជាឲ្យធ្វើបុណ្យថ្វាយព្រះភ្លើងព្រះសព ពញាអុង សាងព្រះវិហារបញ្ចុះធាតុ រួចហើយ ទ្រង់បានយាងចូលបន្ទាយលង្វែកវិញ ។

នៅឆ្នាំ ១៥៣១ ព្រះចន្ទរាជា បានលើកទ័ពទៅរំដោះអាណាខេត្តខាងលិច ដែលបានបាត់បង់ក្នុងរាជ្យមុនៗ ទ្រង់បានរំដោះយកខេត្ត **បស្ចឹមបុរី** មកវិញ ។

ចាប់ពីឆ្នាំ ១៥៥៦ ស្តេចភូមា នាម **បាយិណោង** បានលើកទ័ពមកវាយសៀម ដណ្តើមយកបានរាជធានី **អយុធ្យា** នៅឆ្នាំ ១៥៦៤ ។ ឆ្លៀតពេលនោះ ព្រះចន្ទរាជា បានលើកទ័ពវាយសៀម នៅឆ្នាំ ១៥៥៧ រំដោះយកខេត្ត **ចន្ទបុរី** និង ខេត្តផ្សេងនៅជិតៗនោះ ។ ខ្មែរបានលើកទ័ពវាយសៀមពីរលើកទៀត គឺនៅឆ្នាំ ១៥៥៩ និង ១៥៦២ ហើយចាប់បានសៀមជាឈ្លើយសង្គ្រាមជាច្រើន នាំមកស្រុកខ្មែរ ។ ព្រះចន្ទរាជា បានតាំងស្តេចត្រាញ់ ៥ អង្គ ជាចៅហ្វាយខេត្ត គឺចៅហ្វាយ ខេត្តអាសន្ទ១ ខេត្តពោធិ៍សាត់១ ខេត្តត្បូងឃ្មុំ១ ខេត្តបាភ្នំ១ ខេត្តទ្រាំង១ ។ ទ្រង់បានសោយទីវង្គតនៅក្រុងលង្វែក នៅឆ្នាំ ១៥៦៦ ព្រះអដ្ឋិធាតុតំកល់នៅលើភ្នំ ព្រះរាជទ្រព្យ សព្វថ្ងៃ ។

បុត្រព្រះអង្គ **បរមរាជាទី ៤** (១៥៦៦-១៥៧៦) បានបន្តការងារព្រះបិតាទ្រង់តទៅទៀត គឺការវាយរំដោះយកអាណាខេត្តខាងលិចថែមទៀត ។ នៅឆ្នាំ ១៥៧០ ពេលដែលព្រះអង្គគង់នៅតំបន់អង្គរ ត្រង់ **កំពង់ក្រសាំង** ទ័ពខ្មែរបានរំដោះយកខេត្ត **នគររាជសីមា** ហើយបានដាក់មន្ត្រីឲ្យកាន់ការនៅទីនោះ ។ ទ័ពខ្មែរ បានវាយយកស្រុកតូចៗពីរ **ចន្ទបុរី** ដល់ **ធនបុរី** អាណាខេត្តខាងលិចទាំងមូលពីរ **នគររាជសីមា** ចុះរហូតដល់ **ចន្ទបុរី** បានទាំងស្រុង ។ ស្តេចសៀម បង្ខំចិត្តធ្វើសន្ធិសញ្ញាចងស្ពានមេត្រីជាមួយខ្មែរ នៅឆ្នាំ ១៥៧៤ សុខចិត្តប្រគល់ឲ្យខ្មែរ ខេត្ត **នគររាជសីមា បស្ចឹមបុរី ចន្ទបុរី** ។

**ព្រះសត្ថាទី ១** មាននាមរាជ្យ **ព្រះបរមរាជាទី ៥** (១៥៧៦-១៥៩៥) ជាបុត្រ បាន



ឡើងគ្រងរាជ្យ ពេលដែលព្រះបិតា បរមរាជាទី ៤ សុគតទៅ ។ ចន្លោះឆ្នាំ ១៥៧៤-១៥៨០ ព្រះសត្ថាទី ១ បានវាយក្រុង**ពេជ្របុរី** ៣ ដង និង បានវាយយក **ពេជ្របុរី** ។ ពង្សាវតា ខ្មែរបាននិយាយថា ព្រះសត្ថាទី ១ បានលើកទ័ពទៅវាយក្រុង **អយុធ្យា** ហើយចាប់បានឈ្លើយសៀមជាច្រើន (១៥៧៩-១៥៨០) ។

នៅស្រុកសៀម មានការផ្លាស់ប្តូរច្រើន ។ ឆ្នាំ ១៥៨០ ស្រុកសៀមបានចំណុះស្តេចភូមា បាយិណោង ។ ព្រះរាជបុត្រសៀម នាម **នរេសួរ** បានទៅបំរើស្តេចភូមានៅក្រុង **ហង្សាវតី** ។ ដោយដឹងខ្លួនថា ស្តេចភូមា រកលេសម្លាប់ **នរេសួរ** ក៏បានភៀសខ្លួនរត់មកក្រុងអាយុធ្យា ហើយបានសុំជំនួយពីទ័ពខ្មែរ ។ ដោយគោរពតាមសន្ធិសញ្ញាសន្តិភាពខ្មែរ-សៀម ឆ្នាំ ១៥៧៤ ព្រះ**សត្ថាទី ១** បានបញ្ជាមហាឧបរាជ **ស្រីសុរិយោពណ៌** ជាព្រះអនុជ លើកទ័ពទៅជួយសៀម ។ ទ័ពខ្មែរ បានជួយ នរេសួរ រហូតបានជ័យជំនះលើភូមា ។ តែ នរេសួរ ជាស្តេចរមិលគុណ មានគំនិតចង់វាយយកស្រុកខ្មែរ ដាក់ជាចំណុះ ។ ឆ្នាំ ១៥៨១ ទ័ពខ្មែរបានទៅរំដោះបាន **នគររាជសីមា ចន្ទបុរី** និង **នគរនាយក** ។ ឯកសារសៀម និយាយថា ឆ្នាំ ១៥៨២ នរេសួរ បានវាយយក **នគររាជសីមា** វិញ ។ នរេសួរ បានប្រកាសឯករាជ្យ ឈប់ចំណុះភូមា នៅឆ្នាំ ១៥៨៤ ។ ឯកសារមិនច្បាស់ បាននិយាយថា នរេសួរ ខ្វាល់នឹង ព្រះសត្ថាទី ១ នៅឆ្នាំ ១៥៨៦ ពេលដែលទ័ពភូមាដកចេញ ទ័ពសៀមបានមកវាយបាន **ស្រុកបាត់ដំបង** និង **ស្រុកពោធិ៍សាត់** ហើយក៏លើកទ័ពវិលទៅវិញព្រោះខ្វះស្បៀង ឬក៏ ទ័ពសៀមបានទៅវាយតទល់យ៉ាងខ្លាំង ជាមួយខ្មែរ នៅបាត់ដំបង រួចនៅ**កំពង់ប្រាក់** ។ តែទ័ពសៀមវាយយកបាន **បន្ទាយមានជ័យ** និង **បន្ទាយបរិបូណ៌** ។ ព្រះស្រីសុរិយោពណ៌ នាំទ័ពចូលក្នុង **បន្ទាយលង្វែក** ។ ចម្បាំងលើកនេះ មានទ្រង់ទ្រាយធំណាស់ សៀមមានទ័ពចំនួន ១០ ម៉ឺននាក់ ដំរី ៨០០ និង សេះ ១៨៥០ ។ ទោះបីមានចំនួនច្រើនដូចនេះក្តី ក៏ទ័ពសៀម មិនអាចវាយយក បន្ទាយលង្វែក បានឡើយ ។ ទ័ពសៀម ខ្វះស្បៀង និង មានជម្ងឺរាតត្បាត ក៏ដកថយទៅមួយរយៈ ។ ឯកសារសៀម និយាយថា ទ័ពសៀម ឈឺស្លាប់ច្រើន ដូច្នេះ មកពីបីសាចកាច់ និង នគរខ្មែរមានអ្នកការពារ ។ នរេសួរ បានចាត់ឲ្យសាកសួរ ខ្មែរបានដឹងថា មានទេវរក្ស ១៣ អង្គ ជួយថែរក្សានគរខ្មែរ ។ មុននឹងរត់ទៅ សៀមបានរកឧបាយកលបាញ់ប្រាក់ដួងជាច្រើនក្នុងគុម្ពឫស្សី ដែលជារបងការពារយ៉ាងមាំមួន សម្រាប់ការពារបន្ទាយលង្វែក ។ ព្រះចៅសៀម បានចាត់ចារបុរសពីរនាក់ ចូលធ្វើវិទ្ធង្សនាបង្កើតចលាចល ផ្ទៃក្នុងស្រុកខ្មែរ ៖ មហាតលិកសៀម ពីរនាក់បានក្លែងខ្លួនជាអ្នកបួសនាម **តិបញ្ញោ** និង **សុប្បញ្ញោ** ចូលមកធ្វើពិធីដកសិល្ប៍សាស្ត្រ

ដែលបញ្ចុះក្នុងរូបទេវរក្ស ។ សុប្បញ្ញោ ប្រើមន្តអាគម ធ្វើឲ្យអ្នកស្រុកឈឺ តិបញ្ញោ ជាអ្នកធ្វើមន្តដោះឲ្យជាសះស្បើយ ។ ឆ្នាំ ១៥៨៦ ព្រះសត្ថាទី ១ មិនគិតរកវិធានការទប់ទល់ទៅខ្មាំងសៀម តែបែរជាបង្កើតការមិនទុកចិត្តក្នុងរាជវង្ស ។ ព្រះអង្គ បានប្រគល់រាជ្យទៅឲ្យបុត្រច្បង អាយុ ១១ វស្សា ព្រះនាម **ជ័យជេដ្ឋា** បុត្រាទី ២ ទើបបានអាយុ ៦ វស្សា ឈ្មោះ **ពញាតន់** ឡើងជាឧបរាជ ។ ឯ ព្រះស្រីសុរិយោពណ៌ បានឡើងជា ឧភយោរាជ ។ ទង្វើនេះ ធ្វើឲ្យមានការអាក់អន់ស្រពន់ចិត្តក្នុងរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី រហូតដល់ប្រជានុរាស្ត្រ បង្កើតជា ចោរលួច ចោរប្លន់ កើតឡើងព្រោងព្រាតពេញនគរ ។

ឆ្នាំ ១៥៩៣ សៀម បានលើកទ័ពចូលវាយ លង្វែក ម្តងទៀត ។ នរេសួរ ស្តេចសៀម បានបញ្ជាទ័ពជា បីផ្លូវ ។ ខ្មែរ លើកទ័ពទៅវាយតទល់ តែពេលនេះ ទ័ពសៀមវាយយកបាន **បន្ទាយពោធិ៍សាត់** និង **បន្ទាយបរិបូរ** ។ ព្រះ**ស្រីសុរិយោពណ៌** ចេញបញ្ជាកែន ទ័ពប្រមូលស្បៀង ចូលការពារ **បន្ទាយលង្វែក** ។ ទ័ពដែលចេញទៅទប់ខាង **នគរវត្ត** ក៏ទប់ពុំជាប់ ។ ទ័ពជើងទឹក ក៏ចាញ់សៀមទៀត ។ សៀមវាយកាន់តែខ្លាំងឡើង ព្រះសុរិយោពណ៌ ដកថយមកនៅ **បន្ទាយរលាប្អៀរ** ហើយសុំជំនួយទ័ពពី បន្ទាយលង្វែក ។ សៀម លើកទ័ពមកព័ទ្ធបន្ទាយនេះទៀត ។ ពេលដែលទ័ពសៀមជិតមកដល់ ព្រះសត្ថាទី ១ នាំបុត្រទាំងពីរ ព្រះជ័យជេដ្ឋា និង ពញាតន់ ភៀសទៅគង់នៅ**ស្រីសន្ធរ** ក្រោយមក ភៀសទៅស្ទឹងត្រែង ហើយទីបំផុត ទៅគង់នៅ **វៀងចន្ទន៍** រាជធានីប្រទេសលាវ **លានជាង** ។

ចំណែកឯ ព្រះស្រីសុរិយោពណ៌ ទ្រង់វិលមកគង់នៅបន្ទាយលង្វែក ប្រយុទ្ធនឹងខ្មាំងសៀមទៀត ។ ទោះបីជាខំទប់ទល់យ៉ាងណាក្តី បន្ទាយលង្វែក ត្រូវសៀមឡោមព័ទ្ធអស់រយៈពេល បីខែ សៀមបានយកចំបើង ដុតរបងឫស្សីដែលនៅសេសសល់បន្តិចបន្តួច ហើយបន្ទាយនេះ ក៏បានធ្លាក់នៅឆ្នាំ ១៥៩៣ ។ សៀម បានចាប់ ព្រះ**ស្រីសុរិយោពណ៌** និង បុត្រទាំងពីររបស់ទ្រង់ គឺ ព្រះ**ជ័យចេស្តា** (១៥ វស្សា) និង ព្រះ**ឧទ័យ** (៥ វស្សា) យកទៅស្រុកសៀម ជាមួយក្បួនខ្នាតអ្នកប្រាជ្ញ បណ្ឌិតកវី រូបដិមា**ព្រះគោព្រះកែវ** និង ឈ្លើយខ្មែរជាច្រើន ។ ក្រោយពីបានស្នាក់នៅ ស្រុកខ្មែរ ៣ ខែ នរេសួរ ក៏បានវិលទៅ **អយុធ្យា** វិញ ទុកឲ្យតែ មហាមន្ត្រីសៀម នៅឈរជើងនៅ ក្រុងឧដុង្គ ។ គួរគប្បីរំលឹកថា នៅខាងមុខព្រះ**វិហារព្រះកែវ** នៅក្រុងបាងកកស្រុកសៀមសព្វថ្ងៃ មានរូបបដិមា **ព្រះគោ** ដែលមានទំហំប៉ុនសត្វគោធំ ពោះប្រហោងក្នុង ។

ពីឆ្នាំ ១៤៣២ ឆ្នាំដែលបោះបង់ចោល រាជធានីអង្គរ មកដល់ឆ្នាំ ១៥៩៣ ឆ្នាំដែលបន្ទាយលង្វែក ធ្លាក់ចូលដៃសៀម មហិទ្ធិឫទ្ធិខ្មែរ ចុះខ្សោយឡើងៗ ។ ខ្មែរ លែងក្លាយជា



ម្ចាស់ទឹកដី លើទឹកដីរបស់ខ្លួនទៀតហើយ ៖ ទឹកដីជាន់ក្រៅគឺ ស្រុក**បច្ចន្តជនបទ** ដូចជាស្រុក**សុខោទ័យ** ស្រុក**ស្រីអយុធ្យា** ស្រុក**លពបុរី** ស្រុក**គោកត្របុរ** (ភីម៉ៃ) ត្រូវបាត់បង់អស់ទៅហើយ ឯប្រទេស សាមន្តរាជា ដូចជា **ចាម្ប៉ា អណ្ណាម ជ្វា មន** ក៏លែងមានទៀតដែរ ។ ព្រំដែនខាងជើងស្រុកខ្មែរ ធ្លាក់មកនៅត្រឹម **ទន្លេមូល** ឬ នៅខាងលើនេះបន្តិចបន្តួច និង ប្រទេសលាវ ។ ព្រំដែនខាងលិចទល់នឹង **បស្ចឹមបុរី** និង **រយ៉ង** ខាងពាយ័ព្យទល់នឹងស្រុក **នាងរងនគររាជ** ខាងកើតទល់នឹងប្រទេស **ចាម្ប៉ា** ខាងត្បូងទល់នឹង សមុទ្រចិន និង ឈូងសមុទ្រសៀម ។

តាមរាជពង្សាវតាខ្មែរ រាជាណាចក្រខ្មែរ សម័យនោះ មានប្រមាណ ៧០ ខេត្ត ៖

**លង្វែក អម្រិន្ទបូរ ក្រគរ ត្រង ពោធិ៍សាត់ បាត់ដំបង ឫស្សីសាញ តាមសីមា មង្គលបូរី រយ៉ង សុរិន្ទ សិង្ហារ កំពង់សៀម ស្ទឹងត្រែង ជើងព្រៃ គោកសេះ អន្លង់រាជ ព្រំទេព ព្រៃក្តី ស្មោង ជីក្រែង រលួស សៀមរាប កំពង់ស្វាយ ម្លូព្រៃ ជាំក្សាន្ត ត្នោត ទឹកជោរ សៀមបូក សម្បុកសម្បូណ៌ ក្រចេះ ឆ្លូង ត្បូង បាសាន ទទឹងថ្ងៃ ព្រៃវែង ត្បូងឃ្មុំ បាភ្នំ រំដួល ស្វាយទាប រោងដំរី ព្រៃនគរ លង់ហោរ ដើបោដែង សំរោងទង បាទី លើកដែក ទ្រាំង បន្ទាយមាស ថ្កូងបាសាក់ បារៀ ពាម កោះស្លាកែត កំពត កំពង់សោម ទឹកខ្មៅ ពាមមេសរ ព្រះត្រពាំង ក្រមួនស ដូនណៃ** ។ល។

គួរកត់សំគាល់ថា ក្នុងចំណោមខេត្តទាំងនោះ ខេត្តនៅមានឋានៈជាខេត្តដដែល ដូចជា ៖ ពោធិ៍សាត់ បាត់ដំបង ស្ទឹងត្រែង សៀមរាប ក្រចេះ ព្រៃវែង ។ល។ ឯខ្លះទៀត ចុះឋានៈមកជាស្រុកវិញ ដូចជា ៖ មង្គលបុរី ស្មោង ជីក្រែង រលួស ទឹកជោរ ។ល។ ខ្លះទៀត បាត់ឈ្មោះ រលាយចូលនឹងខេត្តឯទៀតៗអស់ទៅ ហើយនិង ខេត្តប៉ែកខាងលិច និង ខាងត្បូងបាត់ឈ្មោះតែម្តង ដោយសារ សៀម និង យួន លេបាត់ ។

## ព្រះចន្ទរាជា
## (១៥១៦ - ១៥២៥)

ស្តេចកន មានអាយុ ២៩ ឆ្នាំ បានឡើងគ្រងរាជ្យមាននាម ព្រះស្រីជេដ្ឋាធិរាជរាមាធិបតី ។ ទ្រង់បានលើករាជធានីមកតាំងនៅ ចន្លក់ដូនតី (បាន ៥ ខែ) រួចលើកមកតាំងនៅភូមិស្រឡប់ ជាទល់ដែន ខេត្តត្បូងឃ្មុំ និង បាភ្នំ រាជធានីថ្មីនេះមានឈ្មោះថា ក្រុងស្រឡប់ពិជ័យព្រៃនគរ ។

ព្រះចន្ទរាជា ជាព្រះអនុជ ព្រះស្រីសុគន្ធបទ ជាមួយព្រះរាជវង្សានុវង្ស បានភៀសខ្លួនទៅសុំជ្រកកោននឹងស្តេចស្រុកសៀម នៅពេលដឹងថា ស្តេចកន ក្បត់ ។ នៅស្រុកសៀម ព្រះចន្ទរាជា តែងតែទៅទាក់ដំរី យកដំរីថ្វាយស្តេចស្រុកសៀម ។ ពេលដែលដឹងថា ព្រះរៀម បានត្រូវបក្សពួក ស្តេចកន ធ្វើគតហើយ ទ្រង់ក៏រកមធ្យោបាយវិលត្រឡប់មកស្រុកខ្មែរវិញ ។ ទ្រង់បានប្រឌិតថា ទៅទាក់ដំរីស នៅប៉ែកខាងកើតស្រុកសៀម ។ ដំរីសនោះមានកំពស់ ១០ ហត្ថ (៥ ម៉ែត្រ) ។ ព្រះចៅសៀម បានព្រមឲ្យពលចំនួន ៥០០ នាក់ ដំរីធ្នាក់ ៥០ គ្រឿងសាស្ត្រាវុធ ស្បៀងអាហារ និង ដាវអាជ្ញាសឹក ។ ព្រះចន្ទរាជា មិនបានទាក់ដំរីសទេ តែបាននាំទ័ពចូលស្រុកខ្មែរ ទៅដល់ បាត់ដំបង បានកែនពល ១០០០០ នាក់ ហើយលើកទ័ពឆ្ពោះទៅ ពោធិ៍សាត់ ។ តាពេជ្រ ជាមេទ័ពជំនិត ព្រះចន្ទរាជា បានវាយយក ខេត្តក្រគរខ្លងក្រង ។ នៅឆ្នាំ ១៥២៥ ព្រះចន្ទរាជា បានចាត់ឲ្យទៅទិញកាំភ្លើង ធំតូច ពីប្រទេសម៉ាឡាយូ ដើម្បីវាយផ្តាច់ព្រាត់ទៅទ័ព ព្រះស្រីជេដ្ឋា ។ ទ័ព ព្រះចន្ទរាជា ចែកជា បី ផ្លូវ ។ ព្រះអង្គ ទ្រង់នាំទ័ពទៅវាយ**បន្ទាយស្រីសឈរ** (ស្រីសន្ធរ) ដោយផ្ទាល់ព្រះអង្គ ។ ព្រះស្រីជេដ្ឋា និង ចៅហ្វាកៅ (មន្ត្រីក្បត់) ខំវាយទម្លុះរត់ចូលទៅក្នុង**បន្ទាយស្រឡប់ពិជ័យ** ដែលទីបំផុត បន្ទាប់ពីបានតស៊ូ បីខែ មក ទ័ពព្រះស្រីជេដ្ឋា បានទទួលបរាជ័យ ។ ព្រះស្រីជេដ្ឋា ត្រូវគេកាត់ព្រះសិរ យកមកដោតនៅមុខបន្ទាយ ក្រុងស្រឡប់ពិជ័យ ឯចំណែក ចៅហ្វាកៅ ក៏ត្រូវគេសម្លាប់បានក្នុងបន្ទាយនោះដែរ ។ សង្គ្រាមក្នុងស្រុក មានរយៈពេល ៩ ឆ្នាំ (១៥១៦-១៥២៥) បានបញ្ចប់នៅពេលនោះ ។

ព្រះចន្ទរាជា បានឡើងគ្រងរាជ្យនៅឆ្នាំ ១៥១៦ មាននាម ***ព្រះចន្ទរាជា*** ក្រោយពេលរកឃើញ ព្រះខាន់រាជ្យ លំពែងជ័យ និង គ្រឿងបច្ចក្សេត្រ ។ ព្រះអង្គ មានរាជធានីតាំងជាបណ្តោះអាសន្ននៅក្នុង ខេត្តពោធិ៍សាត់ ។ បន្ទាប់មក ព្រះអង្គក៏លើករាជធានីមកគង់នៅ***ក្រុងលង្វែក*** ។ រាជធានីថ្មីនេះ ត្រូវបានកសាងប្រហែល ៣ ឆ្នាំ (១៥២៧-១៥២៩) ។

ពេលដែលដឹងថា ព្រះចន្ទរាជា កាន់អំណាចស៊ប់នៅ ប្រទេសខ្មែរ ហើយ ព្រះចៅ

សៀម ក៏បានទាមទារយកសួយសារអាករពីស្តេចប្រទេសខ្មែរ ដែលប្រទេសនេះ ធ្លាប់បានផ្តល់ឲ្យតាំងពីរាជ្យ ព្រះបាទ ស្រីធម្មរាជាទី ១ (១៤៨៦-១៥០៤) ។ ព្រះចន្ទរាជា ពុំព្រម ។ សៀម បានលើកទ័ពមកលុកលុយ ខេត្តអង្គរ ។ ព្រះអង្គ បានលើកទ័ពខ្មែរទៅតទល់នៅត្រង់ **ស្ទឹងអង្គរ** ត្រង់ភូមិមួយឈ្មោះថា **សៀមរាប** គឺជាអនុស្សាវរីយ៍ដែលទ័ពខ្មែរបានទទួលជោគជ័យលើ ទ័ពសៀម ឈ្លានពាន ។ ដើម្បីជាការសងសឹក នៅឆ្នាំ ១៥៣០ ព្រះចៅសៀម បានបញ្ជា **ពញាអុង** "បុត្រ ព្រះស្រីរាជា (១៤៦៩-១៤៨៥) ក្លាយជាបុត្រធម៌ព្រះចៅសៀម និង បានកាន់តំណែងជា ចៅហ្វាយខេត្ត**សុវណ្ណខាត់លោក**" លើកទ័ព ៩ ម៉ឺននាក់ មកវាយខ្មែរម្តងទៀត ។ ព្រះចន្ទរាជា បានលើកទ័ពទៅតទល់គ្នានៅ ពោធិ៍សាត់ ។ ទ័ពសៀមជើងទឹក ក៏បានឡើងគោកនៅឈូងសមុទ្រសៀមដែរ តែត្រូវទ័ពខ្មែរវាយបាក់រត់ខ្ចាត់ខ្ចាយទៅ ។ នៅសមរភូមិពោធិ៍សាត់ មេទ័ពសៀមបានស្លាប់អស់ជាច្រើន ក្នុងនោះមាន ពញាអុង ផងដែរ ដោយបានត្រូវព្រួញស្លាប់លើខ្នងដំរី ។ ឯពលទាហានសៀម ស្លាប់អស់ពាក់កណ្តាល ដំរីងាប់អស់ជាច្រើន អាវុធយុទ្ធភ័ណ្ឌ ត្រូវបានរឹបអូសយកយ៉ាងសន្ធឹកសន្ធាប់ ។ ព្រះចន្ទរាជា បានបញ្ជាឲ្យធ្វើបុណ្យថ្វាយព្រះភ្លើងព្រះសព ពញាអុង សាងព្រះវិហារបញ្ចុះធាតុ រួចហើយ ទ្រង់បានយាងចូលបន្ទាយលង្វែកវិញ ។

នៅឆ្នាំ ១៥៣១ ព្រះចន្ទរាជា បានលើកទ័ពទៅរំដោះអាណាខេត្តខាងលិច ដែលបានបាត់បង់ក្នុងរាជ្យមុនៗ ទ្រង់បានរំដោះយកខេត្ត **បស្ចឹមបុរី** មកវិញ ។

ចាប់ពីឆ្នាំ ១៥៥៦ ស្តេចភូមា នាម **បាយិណោង** បានលើកទ័ពមកវាយសៀម ដណ្តើមយកបានរាជធានី **អយុធ្យា** នៅឆ្នាំ ១៥៦៤ ។ ឆ្លៀតពេលនោះ ព្រះចន្ទរាជា បានលើកទ័ពវាយសៀម នៅឆ្នាំ ១៥៥៧ រំដោះយកខេត្ត **ចន្ទបុរី** និង ខេត្តផ្សេងនៅជិតៗនោះ ។ ខ្មែរបានលើកទ័ពវាយសៀមពីរលើកទៀត គឺនៅឆ្នាំ ១៥៥៩ និង ១៥៦២ ហើយចាប់បានសៀមជាឈ្លើយសង្គ្រាមជាច្រើន នាំមកស្រុកខ្មែរ ។ ព្រះចន្ទរាជា បានតាំងស្តេចត្រាញ់ ៥ អង្គ ជាចៅហ្វាយខេត្ត គឺចៅហ្វាយ ខេត្តអាសន្ទ១ ខេត្តពោធិ៍សាត់១ ខេត្តត្បូងឃ្មុំ១ ខេត្តបាភ្នំ១ ខេត្តទ្រាំង១ ។ ទ្រង់បានសោយទីវង្គតនៅក្រុងលង្វែក នៅឆ្នាំ ១៥៦៦ ព្រះអដ្ឋិធាតុតំកល់នៅលើភ្នំ ព្រះរាជទ្រព្យ សព្វថ្ងៃ ។

# ស្តេចកន ឬ ព្រះស្រីជេដ្ឋា
## (១៥១២ - ១៥២៥)

ប្រវត្តិសាស្ត្រកម្ពុជា ក្នុងសតវត្សទី ១៦ ជា សតវត្ស ដែលកម្ពុជាបានបាត់ខេត្តខ្មែរខាងលិចមួយចំនួន ដោយសារសៀម ។ បុព្វហេតុមួយដែលមិនអាចបំភ្លេចបានគឺ វិបត្តិក្នុងរាជវង្សខ្មែរ ។ មានមួយរយៈពេលមួយនោះ មាន ស្តេចពានរាជ្យមួយ បានឡើងសោយរាជ្យ ស្តេចនោះ មានឈ្មោះថា ស្តេចកន ។

ក្នុងរជ្ជកាល ស្រីសុគន្ធបទ (១៥០៤-១៥១២) មានរាជធានីនៅ ទួលបាសាន ស្តេចអង្គនេះ បានលើក នាងស ជាស្នំឯក មាននាមថា កេសរបុប្ផា ជាកូនរបស់មន្ត្រីម្នាក់ឈ្មោះ ពិជ័យនាគ និង នាងបាន ។ ប្អូនប្រុសរបស់ នាងស ឈ្មោះ កៅ ឬ កន ត្រូវបានតែងតាំងជា មហាតលិក ក្រោយមកទៀត បានឋានៈជា ឃុនហ្លួងព្រះស្តេច មាននាទីមើលខុសត្រូវលើ ពលព្រះ ទាំងអស់ និង លើកិរិយាមាយាទ នៃ ពលរដ្ឋទាំងអស់ ។

នៅឆ្នាំ ១៥០៩ ព្រះស្រីសុគន្ធបទ ទ្រង់សុបិនឃើញនាគរាជ ចេញខាំព្រះអង្គ ហើយខាំពាំ ស្វេតច្ឆ័ត្រ ថែមទៀត ។ ព្រះអង្គទ្រង់បញ្ជាឲ្យហោរទាយៗថា មានកោលាហល អ្នកបង្កើតគឺ ឃុនហ្លួងព្រះស្តេចកន ដែលកើតនៅ ឆ្នាំរោង (នាគ) ។ ស្របពេលជាមួយគ្នានោះ មានពាក្យបណ្តឹងមកថា មានកើតហេតុចំឡែកផ្សេងៗ នៅក្នុងនគរ ។ ដោយខ្លាចក្រែង ស្តេចកន ក្បត់ដណ្តើមរាជ្យសម្បត្តិ សមដូចទំនាយរបស់ហោរានោះ ព្រះរាជា ទ្រង់បានធ្វើការប្រជុំសំងាត់ នៃ មន្ត្រីជំនិត ដើម្បីរិះរកមធ្យោបាយកំចាត់ ស្តេចកន ឲ្យបាន តែស្នំឯកលបលួចស្តាប់ដឹងការណ៍ ហើយផ្ញើសំបុត្រទៅប្រាប់ប្អូនជាប្រញាប់ ។

ព្រះរាជា ទ្រង់បញ្ជាឲ្យពួកមន្ត្រី រៀបចំដង្ហែព្រះអង្គ ទៅក្រសាលបឹង បង់សំណាញ់កំសាន្តទៅតាមចំណូលព្រះហឫទ័យរបស់ព្រះអង្គ ដែលធ្លាប់តែធ្វើពីមុនៗមក ។ ដូចបានទុកជាមុនស្រេច ព្រះរាជា ទ្រង់ធ្វើកលថា សំណាញ់ព្រះអង្គ ជាប់សំរាស់ លើកពុំរួច ហើយទ្រង់បញ្ជាឲ្យ ស្តេចកន មុជទឹកទៅដោះ ។ ស្តេចកន បានទទួលបញ្ជាហើយ ក៏លោតទៅក្នុងទឹក ធ្វើហាក់ដូចជាពុំដឹងខ្លួន ហើយមុជថយចេញពីកន្លែងនោះឆ្ងាយទៅ ។ ពេលនោះ ពួកបរិវារ ដែលជាជំនិតព្រះរាជា គិតស្មានថា ស្តេចកន បានធ្លាក់ចូលក្នុងអន្ទាក់របស់ខ្លួនហើយ ក៏ប្រញាប់បង់សំណាញ់ព្រមគ្នា គ្របត្រង់កន្លែងដែល ស្តេចកន លោតចុះទៅនោះ ដោយមានបំណងធ្វើឲ្យ ស្តេចកន ជាប់សំណាញ់រើពុំរួច ស្លាប់នៅក្នុងទឹកនោះទៅ ។

លុះបានចាកផុតពីគ្រោះថ្នាក់ហើយ ស្តេចកន បានភៀសខ្លួនទៅដល់ ខេត្តបាភ្នំ ហើយប្រើឧបាយកលបោកបញ្ឆោតពួកចៅហ្វាយខេត្តថា ខ្លួនបានទទួលបញ្ជាពីព្រះរាជា ឲ្យមក



កែនទ័ពទៅកំចាត់ មហាឧបរាជ ចន្ទរាជា ដែលមានចិត្តចង់ឡើងសោយរាជ្យនៅ ក្រុងចតុមុខ ។ ព្រះរាជា លុះបានជ្រាបដំណឹងថា ស្តេចកន នៅរស់ ហើយមានកងទ័ពប្រឆាំងព្រះអង្គថែមទៀត ក៏ទ្រង់បញ្ជាឲ្យ ឪពុក និង បងស្រី ស្តេចកន ហៅត្រឡប់មកវិញ ។ ស្តេចកន ប្រើឧបាយកលម្តងទៀត ដោយប្រាប់ទៅ ពួកចៅហ្វាយខេត្ត និង អ្នកស្រុក ថា ហ្លួងទ្រង់តឿនពីរឿងសង្គ្រាមទៅវិញ ។

ពាក្យឃោសនារបស់ ស្តេចកន បានលេចឮទៅដល់ មហាឧបរាជ ចន្ទរាជា ។ ព្រះអង្គនឹកស្មានថា មានហេតុមិនស្រួល ក៏នាំព្រះរាជវង្សានុវង្សប្រញាប់ប្រញាល់ភៀសខ្លួនទៅសុំជ្រកកោននឹងស្តេចសៀមទៅ ។ កាលដែលយាងទៅ ខេត្តពោធិ៍សាត់ ព្រះចន្ទរាជា ទ្រង់បានសំណាក់ផ្ទះមន្ត្រីម្នាក់ឈ្មោះ ពេជ ហើយទ្រង់បានទំនុកបំរុងផ្សេងៗពីមន្ត្រីរូបនេះ ។ លុះដឹងថា ព្រះចន្ទរាជា ជាព្រះអនុជ ព្រះស្រីសុគន្ធបទ បានយាងផុតពីប្រទេសហើយ ស្តេចកន ក៏ចាប់ផ្តើមការវាយលុកចូលរាជធានី ទួលបាសាន ។ ព្រះរាជា ទ្រង់បានលើកទ័ពចេញតទល់ផ្ទាល់ព្រះអង្គ តែត្រូវទទួលបរាជ័យ ហើយថយទៅកែនទ័ពថែមនៅ ក្រុងចតុមុខ ។ ស្តេចកន លើកទ័ពចេញតាមវាយបែកបន្ទាយភ្នំពេញទៀត ព្រះស្រីសុគន្ធបទ ថយទៅគង់នៅ លង្វែក បន្ទាយនេះ ក៏ត្រូវវាយបែកទៀត ព្រះរាជា ក៏ទៅគង់នៅ ស្រុកបរិបូរ (អម្រិន្ទបូរ) រួចនៅទីបំផុត ទៅគង់នៅ បន្ទាយស្ទឹងសែន ក្នុងខេត្តអាសន្ទុក នៅឆ្នាំ ១៥១២ ។ ពេលនោះ ស្តេចកន បានមកតាំងទ័ពបោះបន្ទាយនៅ ទួលបាសាន ហើយប្រារព្ធពិធីលើកខ្លួនឯងឡើងជា មហាឧបរាជ ។ រួចហើយ ទ្រង់បានបញ្ជាឲ្យទ័ពលើកទៅបោះនៅ កំពង់សៀម ទៀត ។ ស្តេចកន បានក្លែងសំបុត្រផ្ញើទៅហ្លួងសុំចុះចូល តែសុំឲ្យ ម្តាយ និង បងប្អូន បានមកមុនសិន ។ ហ្លួងបានបញ្ជាឲ្យឆ្លើយវិញថា ត្រូវតែ ស្តេចកន ចូលខ្លួនមកមុន បើពុំដូច្នោះទេ នឹងសម្លាប់ ម្តាយ និង បងប្អូន ទាំងអស់ ។ ស្តេចកន លើកទ័ពទៅជិត អាសន្ទុក រកឧបាយកលយក ម្តាយ និង ញាតិសន្តាន មកវិញ ។ ពេលនោះ មានមន្ត្រីម្នាក់ឈ្មោះ ឧកម៉ឺនសុរិន្ទកែវ ស្ម័គ្រចិត្តទទួលបំពេញកិច្ចការនេះ ។ កាលនោះ គេចោទថា មន្ត្រីរូបនេះក្បត់ ស្រាប់តែមានទាហាន ២០០ នាក់ ជួយយកអាសា នាំទៅខាងបន្ទាយហ្លួង សុំចុះចូល ។ បន្ទាប់មក ស្តេចកន នាំទ័ពចូលទៅវាយលុកបន្ទាយ ស្ទឹងសែន យ៉ាងខ្លាំង ។ ដោយទ្រង់ឈ្វេងយល់ថា មិនអាចទប់ទល់យូរអង្វែងតទៅទៀតបាន ព្រះរាជា គិតដកថយតាមជើងទឹក ទៅកាន់ ខេត្តពោធិ៍សាត់ តែពេលនោះ ឧកម៉ឺនសុរិន្ទកែវ និង បក្សពួក បះឡើង ចូលចោមធ្វើគតព្រះអង្គបាន នៅក្នុង បន្ទាយស្ទឹងសែន នោះទៅ នៅឆ្នាំ ១៥១២ ។ ព្រះរាជបុត្រព្រះអង្គ ព្រះនាម ពញាយសរាជា ជាបុត្រជាមួយ អ្នកម្នាង កេសរបុប្ផា និង បរិពារមួយក្រុម បានភៀសខ្លួន

ទៅជ្រកកោននៅប្រទេសសៀម ជាមួយ ព្រះចន្ទរាជា ។

យុនហ្លង ព្រះស្តេចកន ត្រឡប់មក ទួលបាសាន វិញ ប្រកាសឲ្យរក ព្រះខាន់រាជ្យ ព្រះលំពែងជ័យ និង គ្រឿងព្រះបញ្ចក្សេត្រ ដើម្បីឡើងសោយរាជ្យសម្បត្តិ ។ ពេលឡើងសោយរាជ្យនោះ ស្តេចកន មានអាយុ ២៩ ឆ្នាំ នាមរាជ្យ គឺ ព្រះស្រីជេដ្ឋាធិរាជរាមាធិបតី ។ ស្តេចកន បានបញ្ចោមេទ័ព កៅ ជា ឪពុកមាបង្កើត ឲ្យទៅវាយបង្ក្រាបយកខេត្តទាំងឡាយណា ដែលមិនទាន់ចុះចូល ។ ឪពុកមានេះ បានតំឡើងឋានៈជា ស្តេចចៅហ្វាទឡ្ហៈ ពួកបរិវារនានា ក៏បានទទួលយសស័ក្តិទៅតាមគុណបំណាច់រៀងៗខ្លួនដែរ ។

នៅប្រមាណឆ្នាំ ១៥១៨ ព្រះស្រីជេដ្ឋា បានលើករាជធានីមកតាំងនៅ ចន្លក់ដូនតី (៥ខែ) រួចមកតាំងនៅ ក្រុងស្រឡប់ពិជ័យព្រៃនគរ ។

ស្តេចអង្គនេះ ចំណូលហ្វូទ័យខាង បរបាញ់សត្វ ចាប់ត្រី ល្បែងស្រី ទតរបាំមហោស្រពតន្ត្រី ។ ទ្រង់បានបោះ ប្រាក់ស្លឹង (សាច់ប្រាក់សុទ្ធ) មានរូបនាគ សម្រាប់ប្រើប្រាស់ក្នុងប្រទេស ប្រជានុរាស្ត្របានរួចពន្ធដារក្នុងរយៈពេល ១ ឆ្នាំ ។ ឯកសារនិយាយថា រជ្ជកាលស្តេចកន នេះ ស្រុកសម្បូណ៌សប្បាយណាស់ ។

ស្តេចកន ឬ ស្តេចពានរាជ្យ បានត្រូវទ័ព ព្រះចន្ទរាជា ចាប់បាននៅបន្ទាយ ក្រុងស្រឡប់ពិជ័យ កាត់ក្បាលដោតនៅមុខបន្ទាយ ឯ ចៅហ្វាកៅ ក៏ត្រូវបានគេសម្លាប់នៅក្នុងបន្ទាយនោះដែរ នៅឆ្នាំ ១៥២៥ ។

នេះជាឈុតមួយ នៃ សង្គ្រាមក្នុងស្រុក ក្នុងរាជវង្សខ្មែរ សង្គ្រាមដែលផ្អែកលើ សុបិនមិនទុកចិត្តគេឯង គឺវិបត្តិនេះហើយ ដែលខេត្តខ្មែរខាងលិច បានបាត់បង់រហូត ដោយសារសៀម ។

## សន្ធិសញ្ញា បារាំង-សៀម ឆ្នាំ ១៩០៤ និង ឆ្នាំ ១៩០៧

*នៅថ្ងៃទី ៣០ តុលា ២០០៨ បន្ទាប់ពី រដ្ឋសភា និង ព្រឹទ្ធសភា ថៃ បានចេញច្បាប់អនុញ្ញាតឲ្យ រដ្ឋាភិបាលថៃ ធ្វើការចរចាជាមួយ កម្ពុជា អំពីបញ្ហាព្រំដែន នៅព្រះវិហារ និង នៅទីឯទៀតទាំងអស់ នោះ ក្រសួងការបរទេសថៃ បានប្រកាសថា "ប្រទេសថៃឡង់ នឹងប្រកែកចំពោះការផ្ដើមគំនិតទាំងអស់របស់ កម្ពុជា យកផែនទីដែល បារាំង បានគូរពីឆ្នាំ ១៩០៤ ធ្វើជាមូលដ្ឋាន នៃ ការកំណត់សីមាព្រំដែន (រវាងប្រទេសទាំងពីរ)" ។ ការប្រកែករបស់ថៃ ចំពោះសន្ធិសញ្ញា បារាំង-សៀម ឆ្នាំ ១៩០៤ និង ១៩០៧ នេះ ជារឿងដែលបានកើតឡើងជាច្រើនដងមកហើយ ដោយគេយកលេសតែមួយថា ៖ សន្ធិសញ្ញា ឆ្នាំ ១៩០៤ និង ១៩០៧ ជាសន្ធិសញ្ញា "មិនស្មើភាពគ្នា" ព្រោះថា បារាំងសម័យនោះ បានប្រើកម្លាំងបង្ខិតបង្ខំសៀមឲ្យចុះសត្ថលេខា[១] ។ តទៅនេះ គឺជាការរំលឹកនូវហេតុការណ៍ធំៗខ្លះ ក្នុងប្រវត្តិសាស្ត្រ ដែលបង្ហាញអំពី បុព្វហេតុ និង ការចាត់ចែងនានា ដើម្បីសំរេចសន្ធិសញ្ញា បារាំង-សៀម ទាំងពីរនេះ ។*

### ចៅហ្វាបែន បាន "កាត់ទឹកដី" ខ្មែរ ឲ្យសៀម (?)

*នៅឆ្នាំ ១៧៩១ ចៅហ្វាបែន បានភៀសខ្លួនទៅ ក្រុងបឹងកក ជាមួយ យុវព្រះមហាក្សត្រ ព្រះបាទ អង្គអេង ។ នៅឆ្នាំ ១៧៩៤ ព្រះចៅសៀម ព្រះបាទ ចក្រី (រាមា ទី១) បានរៀបអភិសេក ព្រះអង្គអេង ជាថ្មី ជាព្រះមហាក្សត្រ នៃ កម្ពុជា ដើម្បីជាការប្រកាសថា ព្រះអង្គនេះ បានព្រមដាក់ កម្ពុជា នៅក្រោមអធិរាជភាព នៃ ព្រះចៅសៀម ។ បន្ទាប់មក ដោយបានទ័ពសៀមជូនមកផង ចៅហ្វាបែន បាននាំ ព្រះបាទ អង្គអេង មកគង់នៅវាំង ឧត្តុង វិញ ប៉ុន្តែ បែន ត្រូវគេចខ្លួនម្ដងទៀត ពីសត្រូវខ្មែរផ្ទាល់ខ្លួនគាត់ នៅទិសពាយព្យ ហើយតាំងទីកាន់កាប់ទឹកដីយ៉ាងធំមួយ រួមដោយ ខេត្តបាត់ដំបង ស៊ីសុផុន និង អង្គរ (សៀមរាប) ដោយប្រហែលជាត្រូវបាន ព្រះបាទ អង្គអេង យល់ព្រមដែរ[២] ។ បែន កាន់កាប់តំបន់នេះ ដោយបាន សៀម ជួយការពារផង ហើយ បែន ក៏បានបញ្ជូនសួយសារអាករទៅថ្វាយ ព្រះចៅសៀម ដូច ព្រះបាទ អង្គអេង បានបញ្ជូនពី ក្រុងឧត្តុង ទៅដែរ ។ ដោយទឹកដីទាំងនេះ មិនត្រូវបានកាត់ផ្ដាច់ពី កម្ពុជា ដោយប្រហែលជា បែន មិនហ៊ាន ឬ ក៏មិនព្រមកាត់ផ្ដាច់ដែរ ទើប ព្រះចៅសៀម ខំបំបែកបំបាក់ ខ្មែរ កាន់តែខ្លាំងថែមទៀត ដោយរំលោភសំរេចថា ទឹកដី បាត់ដំបង ស៊ីសុផុន សៀមរាប ត្រូវកាន់កាប់ដោយ បែន និង កូនចៅតពូជគ្នារហូតទៅ ។ យ៉ាងណាក្ដី ទឹកដីហ្នឹង ស្ថិតនៅក្រោមការគ្រប់គ្រងខ្មែរ ជានិច្ចកាលរហូតដល់ឆ្នាំ ១៨៦៧ ។ នេះមានន័យទៀតថា ថ្វីត្បិតមានការបែកបាក់ផ្ទៃក្នុងក្ដី ប្រទេស*



*កម្ពុជា នៅមូលទឹកដី ដោយមានខេត្ត បាត់ដំបង ស៊ីសុផុន សៀមរាប ជានិច្ច រហូតដល់ពេល បារាំង ចូលមក ឥណ្ឌូចិន ។ ប៉ុន្តែ តាំងពីឆ្នាំ ១៨៩១ ម្ល៉េះ សៀមបានបង្ហាញផែនទីមួយ ឲ្យពួកបស្ចិមប្រទេសឃើញថា ខេត្តខ្មែរ ដូចជា កោះកុង ក្រាត់ ចន្ទបូរ (ចន្ទបុរី) បាត់ដំបង ស៊ីសុផុន សៀមរាប ម្លូព្រៃ ទន្លេរពៅ និង ស្ទឹងត្រែង ជាទឹកដី នៃ ប្រទេសសៀម ហើយ ហើយទឹកដី កម្ពុជា ដែលនៅសល់ប៉ុន្មាន ក៏នៅក្រោម "សហអធិរាជ្យ" សៀម-យួន ដែរ ។*

### សៀម នៅក្នុងចន្លោះអំណាច អង់គ្លេស និង បារាំង

*ស្ថានភាព កម្ពុជា ខាងលើនេះ បានបន្តរហូតដល់ឆ្នាំ ១៨៦៣ គឺនៅពេលដែល បារាំង បានធ្វើ "សន្ធិសញ្ញា អាណាព្យាបាល"កម្ពុជា ដោយផ្ទាល់ ជាមួយ ព្រះបាទ នរោត្តម បន្ទាប់ពីគេបាន យកបាន ក្រុងសៃហ្គង (ព្រៃគរ ឬ ព្រៃនគរ) នៅឆ្នាំ ១៨៥៩ និង ដីកម្ពុជាខាងក្រោម (បន្ទាប់មក ហៅថា កូសាំងស៊ីន) នៅឆ្នាំ ១៨៦១ ជាអាណានិគមរបស់គេហើយ ។ សៀម ខឹងណាស់នឹងសន្ធិសញ្ញានេះ ហើយបានធ្វើការគាបសង្កត់គ្រប់យ៉ាងឲ្យ ព្រះបាទ នរោត្តម បោះបង់សន្ធិសញ្ញាហ្នឹងវិញ ។ នៅពេលនោះ សៀមមិនហ៊ានចេញមុខប្រឆាំងនឹងអំពើរបស់បារាំងនេះ នៅកម្ពុជា ទេ ត្បិតសៀមក៏ទើបនឹងបានសុំឲ្យបារាំង ផ្ដល់ជំនួយ និង ចូលមកធ្វើជំនួញ នៅប្រទេសសៀមដែរ ។ ត្បិតនៅសម័យនោះ គឺមហាអំណាចអង់គ្លេសទេ ដែលគំរាមខ្លាំងមកលើប្រទេសសៀម បន្ទាប់ពីអង់គ្លេស បានកាត់យកប្រទេសភូមា បញ្ចូលទៅក្នុង "មហាណាចក្រឥណ្ឌា" របស់អង់គ្លេស នៅឆ្នាំ ១៨៥២ រួចបញ្ចូលឥណ្ឌាទាំងមូល ក្រោមរាជ្យ នៃ ចក្រភពអង់គ្លេស នៅឆ្នាំ ១៨៥៨ ហើយកំពុងតែចូលត្រួតត្រាយ៉ាងម៉ឺងម៉ាត់ លើរដ្ឋម៉ាឡេជាច្រើន ដែលសៀមបានចាត់ទុកថា ជារដ្ឋចំណុះរបស់ខ្លួន ។ សភាពការណ៍ទូទៅ នាពេលនោះ គឺមហាអំណាច អង់គ្លេស និង បារាំង កំពុងប្រកួតគ្នាយកភូមិភាគទាំងមូល បែងចែកគ្នា ។ ហេតុនេះ ការខ្វល់ខ្វាយរបស់សៀម នាពេលនោះ គឺខំបង្ការឯករាជ្យនយោបាយ នៃ ក្រុងបឹងកក ក្នុងល្បែងប្រកួតប្រជែងរវាង អង់គ្លេស និង បារាំង និង ខំសាកល្បងចាប់ទុកជាអតិបរិមា នូវអ្វីៗដែលថា ជា "របស់" ផងខ្លួនពីពេលមុននៅក្នុងតំបន់នេះ ។*

*ការពិត ដោយលោកដឹងយល់នូវភាពទន់ទាប នៃ ប្រទេសសៀម ព្រះបាទ មង្កុត (រាមា ទី៤) នៅពេលឡើងសោយរាជ្យ ឆ្នាំ ១៨៥១ បានផ្ដើមបើកប្រទេសសៀមយ៉ាងទូលំទូលាយ ទទួលទំនាក់ទំនងពាណិជ្ជកម្ម ព្រមទាំងរៀបចាត់ការរដ្ឋាភិបាលរបស់បស្ចិមប្រទេស ។ ជនជាតិអង់គ្លេស និង ជនជាតិអឺរ៉ុបឯទៀត ព្រមទាំងអាមេរិកផង ត្រូវបានគេ*

ឲ្យដឹកនាំរដ្ឋបាល ស៊ីវិល និង យោធា របស់សៀមដោយផ្ទាល់ ។ ដោយឡែក ព្រះបាទ មង្គុត ខំបញ្ជូនអគ្គរាជទូត ទៅចរចា និងចុះសន្ធិសញ្ញា "មិត្តភាព ពាណិជ្ជកម្ម និង នាវាចរណ៍" ជាមួយមហាអំណាចនានា ដូចជា អង់គ្លេស អាមេរិក បារាំង ដាណឺម៉ាក ហុលឡង់ អាល្លឺម៉ាញ ជាអាទិ៍ ។ សន្ធិសញ្ញា បារាំង-សៀម មួយ បានចុះនាថ្ងៃទី ១៥ សីហា ១៨៥៦ ឲ្យបារាំងទទួលអត្ថប្រយោជន៍ពាណិជ្ជកម្មជាច្រើន ហើយមានសេរីភាពក្នុងការផ្សព្វផ្សាយសាសនា និង បានទទួលលក្ខខ័ណ្ឌឲ្យនាវាចំបាំងបារាំង បើកចូល ពីសមុទ្រ ដល់ក្រុងបឹងកក តាមមាត់ច្រកទន្លេមេណាម ។ នៅថ្ងៃទី ២៧ មិថុនា ១៨៦១ ព្រះចៅអធិរាជបារាំង ណាប៉ូឡេអុង ទី៣ បានធ្វើពិធីទទួលពួករាជទូតសៀម យ៉ាងមហោឡារិក នៅប្រាសាទហ្វុងតែនប្លូ ដើម្បីសំដែងនូវការរាប់អានជាពិសេស របស់បារាំង ចំពោះប្រទេសសៀម ។ គឺការកែទំរង់រដ្ឋាភិបាល តាមសម័យនិយម និង ការទទួលស្គាល់លើផ្ទៃការទូត ទាំងនេះហើយ ដែលបានលើកកិត្យានុភាពរបស់សៀម នៅមុខភ្នែកបស្ចឹមប្រទេស ឲ្យគេយល់ថា ប្រទេសសៀម អាច "រស់ស្ថិតស្ថេរ" ជានិច្ច ។ ជាបន្ទាប់មក អង់គ្លេស និង បារាំង បានសំរេចផ្តល់លក្ខន្តិកៈឲ្យប្រទេសសៀម ថាជា "រដ្ឋទ្រនាប់" នៅចន្លោះ មហាអំណាចអង់គ្លេស និង មហាអំណាចបារាំង ។ នៅកម្ពុជាវិញ អ្នកបន្តតំណែងពី ចៅហ្វាបែន នៅលើទឹកដីបាត់ដំបង ស៊ីសុផុន សៀមរាប នាពេលនោះ ក៏បានដាក់ខ្លួនទាំងស្រុង ទ្រទ្រង់ព្រះចៅសៀម ហើយដែរ ។

## ជោគជ័យធំមួយ នៃ ការទូតសៀម នៅឆ្នាំ ១៨៦៧

នៅថ្ងៃទី ១១ សីហា ១៨៦៣ ដែល កម្ពុជា ចុះហត្ថលេខាព្រមទទួលសន្ធិសញ្ញា អាណាព្យាបាលបារាំង នោះ កម្ពុជា ជារដ្ឋមួយ មានខេត្តជាច្រើននៅមូលគ្នា ដូចជាខេត្តបាត់ដំបង ស៊ីសុផុន និង សៀមរាប ជាដើម ហើយ កម្ពុជា បានចាកផុតពីអធិរាជភាពរបស់សៀម (និង យួន) ជាស្វ័យប្រវត្តិហើយ ។ ប៉ុន្តែ នៅថ្ងៃទី ១៥ កក្កដា ១៨៦៧ ស្រាប់តែរដ្ឋាភិបាលក្រុងប៉ារីស ចុះសន្ធិសញ្ញាមួយ ជាមួយសៀម ដោយកាត់ខេត្ត បាត់ដំបង ស៊ីសុផុន សៀមរាប ជាមួយនិងខេត្ត ចន្ទបូរ (ចន្ទបុរី) និង ក្រាត់ ព្រមទាំង កោះនៅលើសមុទ្រ ឲ្យទៅប្រទេសសៀម ថាជាថ្នូរ នៃ ការទទួលស្គាល់របស់សៀម ចំពោះអាណាព្យាបាលបារាំងនៅកម្ពុជា គឺថា ឲ្យសៀមសុខចិត្តបោះបង់នូវស្រមោលអធិរាជភាពរបស់ខ្លួននោះទៅ ។ ក្រុងប៉ារីស បានចុះសន្ធិសញ្ញានេះ ដោយយោងតាមសេចក្តីរាយការណ៍ នៃ កុងស៊ុលបារាំង នៅក្រុងបឹងកក គឺថា តាមតែការអះអាងរបស់សៀម ដោយគ្មានសួរយោបល់ព្រះមហាក្សត្រខ្មែរ ឬ អ្នកតំណាងបារាំងប្រចាំកម្ពុជា ឬ អ្នកទេសាភិបាលបារាំង



នៅកូសាំងស៊ីន ជាមុនទេ និង ទោះបីជាស្ថានភាព ប្រជារាស្ត្រ និង នយោបាយ នៅខេត្តទាំងនោះ ពុំមានប្រែប្រួលពីខ្មែរអ្វីក្តី ។ នេះ ជាជោគជ័យយ៉ាងធំមួយ នៃ ការទូតសៀម ។ គឺចាប់ពីពេលនោះហើយ ដែលក្រុងបឹងកកបានឱកាសធ្វើ សៀមូបណីយកម្ម "យ៉ាងសន្សឹមៗ" ក្នុងខេត្តទាំងនោះ ទល់នឹងការតស៊ូស្វិតស្វាញ នៃ ប្រជាជនខ្មែរក្នុងខេត្ត ដែលជាបឋម មិនព្រមរៀនសូត្រ និង និយាយភាសា សៀម ឡើយ[៣] ។

បារាំង បានយល់ពីការភាន់ច្រឡំរបស់ខ្លួនយ៉ាងរហ័សដែរ ជាពិសេស ដោយសារគេខាតបង់ផលប្រយោជន៍អំពីធនធានកសិកម្ម នៃ ខេត្តដែលគេកាត់ឲ្យទៅសៀម និង ដោយគេឃើញថា សកម្មភាពសេដ្ឋកិច្ចក្នុងទឹកដីនោះ វាបែរចរន្តមកខាងកម្ពុជា មិនមែនទៅខាងសៀម និង ខាងអង់គ្លេស ទេ ។ ហេតុនេះ ទើបបារាំងបានខិតខំចូលតាំងទីយ៉ាងមាំមួននៅបាត់ដំបង តែក្នុងការរកស៊ីខាងជំនួញប៉ុណ្ណោះ ក្នុងបំណងទាក់ទាញខេត្តទាំងនោះ ឲ្យចូលមកក្នុងសៃរៀនសេដ្ឋកិច្ចរបស់ពួកខ្លួន ។ រីឯអ្នកកាន់អំណាចខ្មែរ គេចេះតែទាមទារនឹងអ្នកតំណាងបារាំងក្នុងស្រុក ឲ្យបានខេត្តទាំងនោះវិលមកកម្ពុជាវិញដែរ ប៉ុន្តែ គេគ្មានធ្វើអ្វីទៀតទាំងអស់ សំរាប់គោលដៅហ្នឹងទេ ។

## ការពង្រីកប្រទេសឡាវ ដោយបង្ខាតសិទ្ធិកម្ពុជា

នៅពេលនោះ កង្វល់ធំរបស់បារាំង គឺបញ្ហាប្រទេសឡាវ ដែលបារាំងចង់កាន់កាប់ និង ពង្រីកឲ្យបានធំមកវិញ ។ នៅឆ្នាំ ១៨៨៦ លោក អូហ្គូស ប៉ាវី ដែលជាកុងស៊ុលបារាំង ប្រចាំក្រុងលួងប្រាបាង បានលើកបញ្ហាព្រំដែនរវាង ឡាវ និង សៀម ហើយបង្កជាការតវ៉ាជាមួយសៀម ដើម្បីកំណត់សមត្ថកិច្ចរៀងខ្លួន នៅក្នុងតំបន់នោះ ។ ការចរចាគ្នាក្នុងរយៈកាលបីឆ្នាំ មិនបានផ្តល់លទ្ធផលអ្វីសោះ ។ ដើម្បីជាទម្ងន់ នៃ ការទាមទាររបស់ខ្លួន សៀមបានបញ្ជូនកងទ័ពឲ្យឆ្លងទៅតាំងទីនៅតាមបណ្តោយដងទន្លេមេគង្គខាងឆ្វេង និង ក្នុងផ្ទៃកខាងត្បូងនៃប្រទេសឡាវ ចាប់ពី ខេត្តចំប៉ាសាក់ ទៅដល់ចង្កេះជួរភ្នំអាណាម ទោះបីជាបារាំងបានធ្វើការព្រមានជាញឹកញាប់យ៉ាងណាក្តី ។ នៅឆ្នាំ ១៨៨៦ បារាំងផ្តើមវាយប្រហារវិញ ដោយយកទ័ពមកពីប្រទេសអាណ្ណាម ហើយបានសំអាតទីតាំងទ័ពសៀម នៅតាមបណ្តោយដងទន្លេមេគង្គខាងឆ្វេងយ៉ាងរហ័ស និង ផ្តើមកាន់កាប់ភូមិភាគឡាវខាងត្បូង ទាំងអស់ ។ ដោយឡែក នៅក្នុងឈូងសមុទ្រសៀមវិញ ទំនាស់រវាង នាវាបារាំង និង កម្លាំងយាមល្បាតសៀម ក៏កើតមានជាញឹកញាប់ដែរ ។ នៅ ខែកក្កដា ១៨៩៣ នាវាចំបាំងបារាំងពីរគ្រឿង បើកទំលាយរបាំងនៅមាត់ច្រកសមុទ្រ នៃ ទន្លេមេណាម ហើយត្រូវប៉មទាហានសៀមបាញ់បណ្តាលឲ្យទាហានបារាំង របួស និង ស្លាប់ ជាច្រើននាក់ ។ នាវាចំបាំងបារាំងក៏បាញ់តវិញ

យ៉ាងខ្លាំងក្លា ហើយបើកបន្តឡើងទៅទីក្រុងបឹងកក (ថ្ងៃទី ១៤ កក្កដា) ដែលនៅទីនោះ គេតំរង់កាណុងគំរាមបាញ់វាំងស្តេចសៀម (ព្រះបាទ ចុឡាឡុងកន-រាមា ទី៥) និង បិទផ្លូវទន្លេមេណាមតែម្តង ។ នៅថ្ងៃទី ២០ កក្កដា លោក អូគូស ប៉ាវី (ដែលមកធ្វើជាកុងស៊ុលបារាំងនៅក្រុងបឹងកក តាំងពីខែ កុម្ភៈ ១៨៩២) បានធ្វើឱសានវាទមួយ (**UN ULTIMATUM**) ដាក់កំហិតឲ្យស្តេចសៀម ប្រគល់ឲ្យបារាំងនូវ ក្រុងលួងប្រាបាង និង ដងទន្លេមេគង្គខាងឆ្វេងទាំងអស់ ព្រមទាំង កោះក្នុងទន្លេ និង ខេត្តខ្មែរ ស្ទឹងត្រែង ដែលបារាំងនឹងភ្ជាប់ឲ្យឡាវវិញ ។ ពេលនោះ គឺអង់គ្លេស ដែលបានជំរុញ ព្រះបាទ ចុឡាឡុងកន ឲ្យព្រមធ្វើតាមឱសានវាទបារាំង ។ ជាកិច្ចធានា ឱសានវាទនេះ កំណត់ទៀតថា គេត្រូវដកទ័ពទាំងអស់ ពីតំបន់ទំហំទទឹង ២៥ គ.ម. តាមដងទន្លេមេគង្គខាងស្តាំ (ដែលជាអតីតទឹកដី ឡាវ និង ខ្មែរ) និង ដកទ័ពទាំងអស់ដែរពីខេត្ត បាត់ដំបង ស៊ីសុផុន និង សៀមរាប ។ នៅឯម្តុំឈូងសមុទ្រសៀមវិញ បារាំងត្រូវបានដាក់ទ័ពត្រួតត្រា ខេត្តចន្ទបូរ (ចន្ទបុរី ឬ ចន្ទប៊ុន) ប៉ុន្តែ សៀមនៅតែកាន់ខេត្ត ក្រាត់ (ត្រាត) និង កោះកុង ជានិច្ច ។ បារាំង និង សៀម ក៏ចុះសន្ធិសញ្ញាមួយនៅថ្ងៃទី ៣ តុលា ១៨៩៣ ជាការពង្រីកប្រទេសឡាវ ដោយបង្ខាតសិទ្ធិកម្ពុជា ថែមទៀត ។ លុះដល់ឆ្នាំ ១៩០១ ទើបសៀមព្រមព្រៀងឲ្យបារាំងចូលកាន់កាប់ ខេត្តក្រាត់ (ត្រាត) នោះដែរ ដោយពិតជាគេត្រូវត្រួតត្រាការដឹកជញ្ជូននៅតាមបណ្តោយឆ្នេរសមុទ្រខ្មែរ នៅទីនោះជាចាំបាច់ ។

## ព្រំដែន នៃ ឥណ្ឌូចិន បារាំង (ឆ្នាំ ១៩០៤)

ប៉ុន្តែ នៅទីផ្សេងៗទៀត ទំនាក់ទំនងរវាង សៀម និង បារាំង នៅតែពិបាកជានិច្ច ដោយសៀមមិនព្រមគោរពតាមការកំណត់នយោបាយ នៃ សន្ធិសញ្ញាឆ្នាំ ១៨៩៣ នោះទេ ។ ដោយរំលោភលើតំបន់គ្មានទ័ពនានាខាងលើ សៀមតែងតែលួចបញ្ជូនទ័ពឲ្យឆ្លងទៅក្នុងប្រទេសឡាវ និង ក្នុងខេត្តខ្មែរខាងជើង ។ តាមរបាយការណ៍បារាំងនៅពេលនោះ ពួក “ចោរ”មកពីសៀម តែងតែចូលមកលួចប្លន់ និង ធ្វើការបំផ្លាញផ្សេងៗ ក្នុងខេត្តបាត់ដំបង (ជាពិសេសនៅ អរញ្ញ ប៉ោយប៉ែត ស៊ីសុផុន) និង ក្នុងខេត្តខ្មែរតាមមាត់សមុទ្រ ។ ដោយឡែក នៅប្រទេសម៉ាឡេស៊ី ចក្រភពអង់គ្លេសបានសំរេចដាក់ស្នងការរបស់គេ មកត្រួតត្រារដ្ឋត្រេងកានូ និង រដ្ឋកឺឡាន់តាន់ ដោយគេចង់ធ្វើការផ្ទាល់ជាមួយនឹងរដ្ឋពីរនេះតែម្តង ដែលជាការរំលោភលើសេចក្តីប្រកាសរួមរបស់ អង់គ្លេស-បារាំង ពីឆ្នាំ ១៨៩៦ ស្តីអំពីតំបន់នេះ ហើយសៀមគ្មានបញ្ចេញប្រតិកម្មអ្វីសោះ ។ នៅក្នុងស្ថានភាពនេះ លោក ប៉ូល ឌូមែរ អគ្គទេសាភិបាល នៃ ឥណ្ឌូចិន-បារាំង បានធ្វើការចរចាជាមួយសៀម ហើយចាប់ពីឆ្នាំ



១៨៩៩ ទៅ ភាគីទាំងពីរក៏ចាប់ប្រជុំគ្នា ដោះស្រាយបញ្ហាសេសសល់ ក្នុងរឿងឡាវ ជាពិសេស ។ ម្តងនេះ ការចរចាមានរយៈកាលប្រាំឆ្នាំ មិនមែនតែ ពីរ-បី ខែ ដូចនៅឆ្នាំ ១៨៩៣ ទេ មុននឹងបានសំរេចនូវអនុសញ្ញា បារាំង-សៀម ចុះថ្ងៃទី ១៣ កុម្ភៈ ឆ្នាំ ១៩០៤ ។ នៅពេលនោះ ទោះជាការចង់បានខេត្ត បាត់ដំបង និង សៀមរាប ឲ្យវិលមកកម្ពុជាវិញ នៅជាប់នឹងស្មារតីមនុស្សទូទៅក្តី ក៏ភាគីបារាំង មិនបានដាក់រឿងហ្នឹងក្នុងបញ្ជី នៃ ការទាមទាររបស់គេទេ ។

នៅពេរនោះ បារាំងគិតតែពីរឿង កំណត់ព្រំដែនរវាង ឥណ្ឌូចិន បារាំង និង សៀម ពីខាងជើង ទៅខាងត្បូង ប៉ុណ្ណោះ ។ គេត្រូវកត់សំគាល់ថា ការចរចាគ្នាបានធ្វើឡើងនៅលើមូលដ្ឋាន នៃ អនុសញ្ញា និង សន្ធិសញ្ញា ដែល បារាំង និង សៀម បានចុះជាមួយគ្នាក្នុងកន្លះសតវត្សកន្លងមក និង លើច្បាប់មនុស្សទូទៅ និង ក្បួនខ្នាត នៃ ទំនាក់ទំនងអន្តរជាតិ នាសម័យនោះ ។ម្យ៉ាងទៀត ការចរចាទាំងនេះ ពិតជាធ្វើឡើងក្រោមការពិនិត្យដោយយកចិត្តទុកដាក់ នៃ មហាអំណាចឯទៀតៗ ដែលមានវត្តមាននៅ ប្រទេសសៀម និង នៅតំបន់នោះ ជាពិសេស ចក្រភពអង់គ្លេស ។ អាស្រ័យហេតុនេះ ទើបទោះជាបារាំងមានប្រៀបក្នុងកម្លាំងយោធាលើសៀមជាច្រើនក្តី ក៏គេឃើញថា ការទាមទាររបស់បារាំងមានលក្ខណៈតិចតួចណាស់ បើប្រៀបទៅការសង្គ្រប់យករបស់អង់គ្លេស និង ជាពិសេស បើគេគិតអំពីការទាមទារដ៏ត្រឹមត្រូវ នៃ ប្រទេសឡាវ និង ប្រទេសកម្ពុជា ពីសៀមមកវិញនោះ ។

តាមអនុសញ្ញា ឆ្នាំ ១៩០៤ នេះ បារាំងបានយក ទីក្រុងហ្លួងប្រាបាង និង ទឹកដីទាំងអស់នៅលើដងទន្លេមេគង្គខាងឆ្វេង ហើយទុកទឹកដីទាំងអស់នៅលើដងទន្លេមេគង្គខាងស្តាំ ឲ្យសៀម ។ រាជាណាចក្រចម្ប៉ាសាក់ ដែលត្រូវឲ្យមកកម្ពុជា គេបានភ្ជាប់ទៅប្រទេសឡាវដែរ ។ ចំពោះកម្ពុជា បារាំងបានយកឲ្យវិញនូវខេត្តតូចៗពីរគឺ ម្លូព្រៃ និង ទន្លេរពៅ ហើយព្រមទទួលយកកំពូលជួរភ្នំដងរែក ជាព្រំដែនជាមួយសៀម ។ នៅខាងត្បូង បារាំងបានយកមកវិញនូវ ខេត្តក្រាត់ (ត្រាត) និង កោះកុង ប៉ុន្តែ ដកខ្លួនពីខេត្តចន្ទបុរី (ចន្ទប៊ុន) ទុកឲ្យសៀម ដើម្បីជាការកំណត់ចែកគ្នាច្បាស់អំពីសមត្ថកិច្ចរៀងខ្លួន ក្នុងឈូងសមុទ្រសៀម កុំឲ្យកើតមានជម្លោះដូចកាលឆ្នាំ ១៨៩៣ ទៀត ។ អនុសញ្ញា ឆ្នាំ ១៩០៤ នេះ បានកំណត់ច្បាស់លាស់នូវឋានលេខា នៃ ព្រំដែន រួចគេបានចាត់តាំងគណៈកម្មការចំរុះ បារាំង-សៀមមួយ សម្រាប់ការកំណត់ព្រំដែននៅលើទឹកដីផ្ទាល់ ។ ប៉ុន្តែ ភាគ “ចំណេញ” របស់បារាំងវាតិចតួចពេកណាស់ នៅមុខសេចក្តីទន្ទឹងរបស់កម្ពុជា ។

## ការទាមទារ នៃ ព្រះបាទ ស៊ីសុវត្ថិ

អនុសញ្ញា ឆ្នាំ ១៩០៤ មិនបានបង្វិលខេត្ត បាត់ដំបង និង សៀមរាប ឲ្យមកកម្ពុជាវិញទេ ។ នៅមុខការមិនពេញចិត្តរបស់ខ្មែរ បារាំងបានយកមកប្រគល់ឲ្យខ្មែរវិញនូវ ខេត្តស្ទឹងត្រែង ដែលគេបានឲ្យទៅឡាវយ៉ាងអយុត្តិធម៌ ពីឆ្នាំ ១៨៩៣ ។ ព្រះបាទ ស៊ីសុវត្ថិ ដែលទើបនឹងបានឡើងគ្រងរាជ្យ បានតវ៉ាយ៉ាងខ្លាំងក្លា ។ ក្នុងលិខិត ចុះថ្ងៃទី ៨ វិច្ឆិកា ១៩០៦ ជូនទៅអ្នកប្រចាំការជាន់ខ្ពស់បារាំងនៅកម្ពុជា និង នៅមុនពេលដែលគណៈកម្មការចំរុះផ្ដើមធ្វើកិច្ចការ លោកបានរៀបរាប់បញ្ជាក់អំពី “សេចក្ដីសង្កេត និង លក្ខខ័ណ្ឌបំរុងទុក” របស់លោកយ៉ាងច្បាស់លាស់ ។ ព្រះបាទ ស៊ីសុវត្ថិ យល់ថា ហេតុដែលសៀមព្រមឲ្យទឹកដីខ្លះមកខ្មែរវិញនោះគឺពីព្រោះសៀម “មិនចង់ទុកវាតទៅទៀត ដោយគេមិនអាចទាញផលបានគ្រប់គ្រាន់ ទៅទប់នឹងការចំណាយសំរាប់ ការងារយកផល ការងារអភិបាល និង ការងារថែទាំ របស់គេប៉ុណ្ណោះ” ប៉ុន្តែគេបានទុក “ខេត្តសម្បូរណ៍ធនធានជាងគេគឺ បាត់ដំបង និង សៀមរាប... ទោះជាខេត្តទាំងពីរនេះ ក៏ដូចខេត្តឯទៀតៗដែរ មិនដែលត្រូវបានព្រះមហាក្សត្រអង្គណាមួយមុនៗខ្ញុំ កាត់ឲ្យទៅសៀមទេ” ។ ហេតុនេះ ព្រះអង្គទាមទារឲ្យគេបង្វិលខេត្ត បាត់ដំបង និង សៀមរាប មកកម្ពុជាវិញ ដោយលោកបញ្ជាក់ផងថា “នៅក្នុង ខេត្តសៀមរាប នេះ ក៏មាននៅឡើយ នូវប្រាសាទជាច្រើន នៃ អតីតរាជធានីដ៏ខ្លាំងពូកែរបស់យើង ដែលជាភស្ដុតាងយ៉ាងចិញ្ចែងចិញ្ចាច នៃ អនុភាពរបស់ដូនតាយើង” ។ ព្រះអង្គបានទាមទារបន្ថែមទៀត ឲ្យសៀមបង្វិលឲ្យខ្មែរវិញដែរ នូវខេត្តខាងជើងឯទៀតគឺ គុជខ័នព្រៃស ស្ទឹងពោធិ៍ ស៊ុរិន សង្កាច នាងរោង នគររាជសីមា (កូរ៉ាត) ដោយមិនយកជួរភ្នំដងរែក ជាព្រំដែលរវាង កម្ពុជា និង សៀម ទេ ។ នៅខាងលិច ជាមួយគ្នានឹង កោះកុង និង ក្រាត់ ខេត្តចន្ទបូរ (ចន្ទប៊ុន) ក៏ត្រូវត្រឡប់មកកម្ពុជាវិញដែរ គឺដូចគ្នា និង “ខេត្វទាំងអស់ដែលមានខ្មែររស់នៅជានិច្ច ហើយនៅតែរក្សាចិត្តស្នេហាជាតិខ្មែរ ជាដាច់ខាត” ។ នៅទីបញ្ចប់ ព្រះបាទ ស៊ីសុវត្ថិ បានដាក់កំហិតថា បើគេមិនប្រគល់ខេត្ត បាត់ដំបង និង សៀមរាប ព្រមទាំងទឹកដីរួមជាមួយខេត្តទាំងនេះ ឲ្យកម្ពុជាវិញទេ នោះ “យើងសុំដាក់លក្ខខ័ណ្ឌបំរុងទុក សម្រាប់យើង និង សម្រាប់អ្នកស្នងរាជ្យបន្តពីយើង នូវសិទ្ធិ នៃ ការទាមទាររបស់យើង លុះត្រាតែគេផ្ដល់ យុត្តិធម៌ និង ការសមចិត្ត យ៉ាងពេញលេញឲ្យយើងវិញ ។

## ការដោះដូរគ្នា និង ការភ្លេចភ្លាំង ក្នុងសន្ធិសញ្ញា ឆ្នាំ ១៩០៧

បារាំង ហាក់ដូចជាយល់អំពីការទាមទាររបស់ ព្រះបាទ ស៊ីសុវត្ថិ ចំពោះខេត្ត បាត់ដំបង និង សៀមរាប ដែរ ដោយបានឃើញស្ថានភាពល្អ នៃ ប្រជារាស្ត្រ និង ភូមិសាស្ត្រ របស់



ខេត្តទាំងពីរ និង បានឃើញដែរថា ចំនួនមនុស្សច្រើន និង ធនធាននៅក្នុងខេត្តនោះ ពិតជានឹងផ្ដល់ចំណូលយ៉ាងសំខាន់ ទៅឲ្យថវិកា នៃ របបអាណាព្យាបាលរបស់គេមិនខាន ។ ម្យ៉ាងទៀត ការនាំយកខេត្តទាំងនេះ មកឲ្យកម្ពុជាវិញ វាគ្រាន់តែជាសំណង នៃ ការភាន់ច្រឡំរបស់បារាំងនៅឆ្នាំ ១៨៦៧ ប៉ុណ្ណោះ ។ ហេតុនេះ គណៈកម្មការចំរុះ បានសំរេចបង្វិលខេត្ត បាត់ដំបង ស៊ីសុផុន និង សៀមរាប មកឲ្យខ្មែរ ប៉ុន្តែ បានកាត់ឲ្យសៀមនូវ ដីអរញ្ញ និង បរិវេណខាងជើងទំហំ ៦០ គម$^២$ ជាមួយនឹង ខេត្តក្រាត់ (ត្រាត) និង ស្រុកដន់សាយ ដែលជាកន្លែងយុទ្ធសាស្ត្រមួយសំខាន់ ព្រមទាំងស្រុកខ្លះទៀតនៅខាងឡាវផង ។ ក្នុងពេលនោះដែរ គណៈកម្មការចំរុះ បានកំណត់ជាស្ថាពរនូវព្រំដែនសមុទ្ររវាង សៀម និង ឥណ្ឌូចិនបារាំង (កម្ពុជា) ក្នុងឈូងសមុទ្រសៀម តាមបន្ទាត់ដែលភ្ជាប់កំពូលខ្ពស់បំផុត នៃ កោះគុតមកចំណុចដី នៃ ឆ្នេរសមុទ្រខ្មែរ នៅទល់មុខនឹងកោះនោះ[៤] ។ ការកំណត់បន្ទាត់ព្រំដែនទាំងនេះ ត្រូវបានចុះក្នុងសន្ធិសញ្ញា ថ្ងៃទី ២៣ មិនា ១៩០៧ ដោយគេគ្មានគិតដល់បន្តិចបន្តួច អំពីលក្ខន្តិកៈ នៃ បណ្ដាខេត្តឯទៀត និង ប្រជាជនខ្មែររស់នៅខាងជើងភ្នំដងរែក និង ខាងលិច នៃ ខេត្តបាត់ដំបង ដែល ព្រះបាទ ស៊ីសុវត្ថិ បានទាមទារយ៉ាងត្រឹមត្រូវនោះទេ ។

ក្នុងទីបំផុត កម្ពុជាមិនបានទទួលអ្វីធំដុំទេពីទឹកដីរបស់ខ្លួន ដែលសៀមបានកាត់យក “ដោយប្រើកម្លាំង នឹង ប្រើពុតត្បុត” (តាមយោបល់របស់ ព្រះបាទ ស៊ីសុវត្ថិ) នៅសតវត្សទី ១៩ មុនពេលបន្តិចដែលបារាំងមកដល់ ។ ក្នុងការចរចាជាបន្តបន្ទាប់របស់ខ្លួនជាមួយនឹងសៀម បារាំងមិនបានយក កម្លាំង និង ឆន្ទៈខ្លួន ទៅសង្កត់បង្ខំសៀមទេ ហើយគេតែងតែធ្វើការដោះដូរគ្នាដោយ “សមធម៌” ជានិច្ច ក្នុងក្របខ័ណ្ឌ សៀម-ខ្មែរ, សៀម-ឡាវ ឬ សៀម-ឥណ្ឌូចិនបារាំង ។ កិច្ចការ នៃ គណៈកម្មការចំរុះ បារាំង-សៀម បានធ្វើឡើងរហូតដល់ឆ្នាំ ១៩០៨ “នៅក្នុងគំនិតស្មារតី នៃ ការទុកចិត្តគ្នាទាំងស្រុង” នេះតាមសំដីនៅក្នុងលិខិតចុះថ្ងៃទី ៩ មិថុនា ១៩០៨ ដែលរដ្ឋមន្ត្រីក្រសួងការបរទេសសៀម បានធ្វើថ្លែងអំណរគុណជាបន្ទាប់ ដល់រដ្ឋមន្ត្រីក្រសួងអាណានិគមបារាំង ដោយគេបានបញ្ជាក់ច្បាស់ថា “ឥរិយាបថ (របស់ពួកបារាំង នៃ គណៈកម្មការចំរុះ) ត្រូវបានគេលើកសរសើរយ៉ាងខ្ពង់ខ្ពស់នៅគ្រប់មជ្ឈដ្ឋានសៀមទាំងអស់” ។ លោក សារិន ឆាក ក៏បានយល់ដែរថា “គោលបំណងនយោបាយ ដែលបារាំងចង់បានជាបន្ទាប់នោះ ជាមូលដ្ឋានធំមួយ នៃ ការកំណត់បន្ទាត់ព្រំដែន ដែលធ្វើឲ្យគេព្រមកាត់ទឹកដីខ្មែរជាច្រើន ឲ្យទៅសៀម”[៥] ។ ហេតុនេះ ការចុះសន្ធិសញ្ញា ឆ្នាំ ១៩០៤ និង ឆ្នាំ ១៩០៧ ជាជោគជ័យមួយធំទៀត នៃ ការទូតសៀម ដែលបារាំងខំផ្ទាក់ផ្ទមនៅពេលនោះ ដើម្បីគំរោងសហការជាមួយគ្នាក្នុងអនាគតកាលទៀត

នៅចំពោះមុខទំហ៊ឹងចក្រភពនិយមអង់គ្លេស[៦] ។ បន្ទាប់ពីការចុះហត្ថលេខាលើសន្ធិសញ្ញានេះ ទំនាក់ទំនងរវាង បារាំង និង សៀម បានឡើងពណ៌សម្បុរល្អជាថ្មីវិញមែន ៖ ចាប់ពីឆ្នាំ ១៩០៨ នោះដែរ ពួកអ្នកច្បាប់បារាំងជាច្រើននាក់ ត្រូវបានក្រុងបឹងកកបន្តុកបណ្ដាក់ឲ្យរៀបចំប្រព័ន្ធច្បាប់សៀមទាំងមូល ជាថ្មី គឺថា ជាបន្ទុកមួយ នៃ ការទុកចិត្តគ្នាយ៉ាងធំមែន ។

ប៉ុន្តែ ការស្រេកឃ្លានវាតទីនិយមរបស់សៀម មកលើទឹកដីខ្មែរ ដូចគ្នានឹងការស្រេក-ឃ្លានរបស់យួនដែរ គ្មានអ្វីអាចសំរន់បានទេ ។ សៀមបានជំទាស់ជាថ្មីនឹងព្រំដែន ឆ្នាំ ១៩០៧ នេះ នៅគ្រប់ឱកាសទាំងអស់ នៅទសវត្ស ១៩២០ និង ១៩៣០ រួចបានទទួលស្គាល់វិញនៅ ឆ្នាំ ១៩២៥ និង ឆ្នាំ ១៩៣៧ ។ ប៉ុន្តែ នៅឆ្នាំ ១៩៤០ បន្ទាប់ពីបារាំងរលំក្រោមកម្លាំងរបស់ ហ៊ីត្លែរ នៅអឺរ៉ុប ប្រទេសថៃឡង់ នៃ របប ភីបុល សុងក្រាម បានបរិហារសន្ធិសញ្ញាឆ្នាំ ១៩០៤ / ១៩០៧ ទាំងស្រុងតែម្ដង ហើយទាមទារ និង ចូលកាន់កាប់ខេត្ត បាត់ដំបង ស៊ីសុផុន និង សៀមរាប ជាថ្មី (ចាប់ពីឆ្នាំ ១៩៤១ ទៅ) ដោយបានជំនួយពីប្រទេសជប៉ុន ដែលឈ្នះ បារាំង និង អង់គ្លេស នៅឥណ្ឌូចិន ។ គេត្រូវរង់ចាំថ្ងៃទី ១៧ វិច្ឆិកា ១៩៤៦ បន្ទាប់ពី ជប៉ុន និង សម្ព័ន្ធមិត្តថៃ ចាញ់គេវិញ ទើបខេត្តទាំងបីនោះបានវិលមកឥណ្ឌូចិនបារាំង (កម្ពុជា) វិញ ដោយសារការចរចាយ៉ាងពិបាកម្ដងទៀតនៅក្នុង "គណៈ-កម្មការចំរុះ សម្រួលគ្នា" មួយ នៅទីក្រុងវ៉ាស៊ិនតុន (ស.រ.អ.) ។ នៅថ្ងៃនោះ អ្នកតំណាងប្រទេសថៃឡង់ បានថ្លែងជាផ្លូវការថា ការដោះស្រាយអំពីការទាមទារទឹកដីរបស់ថៃឡង់ ពីឡាវ និង កម្ពុជា បានចប់ដាច់ស្រាច់ហើយ ។ ការពិត គឺជាការ "ចប់ដាច់ស្រេច" ជាបណ្ដោះអាសន្នទៀត ពីព្រោះដល់ឆ្នាំ ១៩៥៨ ថៃឡង់ នៃ របប សារិត ថាណារ៉ាត បានប្រកែកមិនទទួលស្គាល់ថា ប្រាសាទព្រះវិហារ ស្ថិតក្នុងដីខ្មែរទេ... ។

ក្រុងប៉ារីស, ថ្ងៃទី ១០ ធ្នូ ២០០៨

ឌី ការេត

អនុប្រធាន នៃ គណៈកម្មាធិការព្រំដែនកម្ពុជា

ប្រចាំ ប្រទេសបារាំង និង ក្នុងពិភពលោក

(១)- សូមប្រៀបធៀបនឹងករណីយួន ដែលបានចូលកាន់កាប់កម្ពុជា ចាប់ពីថ្ងៃទី ៧ មករា ១៩៧៩ ហើយបានប្រកាសថា ផែនទីព្រំដែន ដែលបារាំងបានគូសទុកមកនោះ មានភាព "មិនច្បាស់លាស់" ហេតុនេះ បានបង្កើត "តំបន់ស" នៅព្រំដែន ខ្មែរ-យួន ជាច្រើនកន្លែង ។

(២)- ក្នុងសៀវភៅរបស់ អាដេម៉ារ ឡឺក្លែរ **ADHÉMARD LECLÈRE, HISTOIRE DU CAMBODGE DEPUIS LE 1ER SIÈCLE DE NOTRE ÈRE, PAUL GEUTHNER, PARIS 1914, P 401.**



(៣)- ក្នុងសៀវភៅរបស់ អាឡាំង ហ្វូរេស **ALAIN FOREST, LE CAMBODGE ET LA COLONISATION FRANÇAISE, L'HARMATTAN PARIS, 1980, P 175.**

(៤)- ក្នុងកំណត់ហេតុរបស់គណៈកម្មការចំរុះ បារាំង-សៀម ថ្ងៃទី ៨ កុម្ភៈ ១៩០៨ នៅប៉ៃលិន ។

(៥)- ក្នុងសៀវភៅរបស់ សារិន ឆាក **SARIN CHHAK, LA FRONTIÈRE KHMERO-THAÏLANDAISE, THÈSE DE DROIT PUBLIC, DACTYLOGRAPHIÉE, PARIS 1966.**

(៦)- នៅឆ្នាំ ១៩០៩ សៀមត្រូវបោះបង់ រដ្ឋម៉ាឡេ ចំនួនបួនទៀត ឲ្យទៅអំណាចអាណាព្យាបាលអង់គ្លេស ។

(៧)- ក្នុងសៀវភៅរបស់ ព្យែរ ហ្វីស្សេ **PIERRE FISTIÉ, LA THAÏLANDE, PRESSE UNIVERSITAIRE DE FRANCE, PARIS 1971, P 58.**




ផែនទីឥណ្ឌូចិន រៀបរៀងដោយអ្នកតំណាងរាស្ត្របារាំង ហ្វ្រង់ស្វ័រ ដឺឡុង ឆ្នាំ ១៨៨៩
ដែលយកតាមលំនាំផែនទីនានា ផ្នែកក្រសួងភូមិសាស្ត្រ នៃ កងទ័ពបារាំង នៅឥណ្ឌូចិន
តាមឯកសារនានា នៃ អណ្ណាម តុងកឹង និង ថៃ ព្រមទាំងការរុករក តាមដំណើរ និង តាម
បេសកកម្មនានា ដែលបានធ្វើឡើងក្នុងពេលចុងក្រោយបំផុត ។




ប្រទេសកម្ពុជា សតវត្សទី ១៦ (មុនបែក បន្ទាយលង្វែក)

# 90 ans: le Cambodge placé sous le protectorat français de 1863 à 1953

**11 août 1863 traité entre le roi Norodom et Doudard de Lagrée, lieutenant de vaisseau,** Représant de la France auprès du roi. Norodom signe le traité par lequel la France transforme les droits de suzeraineté de l'Annam (désormé colonisé) sur le Cambodge en un **Protectorat.**

**1er décembre 1863 :** Norodom reconnaît la suzeraineté de Bangkok et valide l'annexion par le Siam des provinces et Battambang, Sisophon, Siem Reap, Mlou Prey, Tonlé Repou, Kampong Svay et Pursat.

**15 juiilet 1867, traité franco-siamois :** le Siam renonce à sa suzeraineté sur le Cambodge, mais conserve les provinces annexées. Fin de la double suzeraineté des deux pays voisins.

**23 mars 1907, traité franco-siamois :** Restitution au Cambodge des provinces de Battambang, Sisophon et Siem Reap.







**14 février 1925, traité franco-siamois :** Confirmations des frontières adoptées en 1907.

**7 décembre 1937, traité franco-siamois :** Confirmation du traité 1925. Les deux parties se soumettent aux règles de la Cour Internationale de la Justice (CIJ) de Lahaye en cas de conflit.

**31 janvier 1939 :** Lettre du Gouverneur général de l'Indochine, Jules Brevié, à propos des frontières maritimes entre la Cochinchine et le Cambodge.

**9 mai 1941, signature de la convention franco-siamoise à Tokyo :** La France doit céder à la Thailande la province de Battambang et une partie importante des provinces de Siem Reap, Kampong Thom et Stung Trèng, à l'exception du complexe des temples d'Angkor.

**17 novembre 1946 :** Règlement franco-siamois annulant la convention de 1941. Retour au Cambodge des provinces occupées par la Thaïlande de 1941. Le traité franco-siamois de 1937 est remis en vigueur. La Thaïlande maintient unilatéralement ses gardiens sur le site du temple du Preah Vihear.

**5 juin 1949 :** Malgré la protestation d'un groupe parlementaire dirigé par Gaston Deferre, l'Assemblée nationale française a voté le rattachement la Cochinchine à l'Annam.

**9 novembre 1953 :** Le roi Norodom Sihanouk proclame l'Indépendance du Cambodge.



